ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jan-2015, 10:31
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី២២៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ៉័ង

កញ្ញា រ៉ូប៊ីន្នី ក្រូហ្វត៍ *(Ms. Robynne CROFT)*

លោក ម៉ាធូវ ម៉ាកាធី
*(Mr. Matthew MCCARTHY)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

លោក សេង លាង

លោក ស្រ៊ា រតនៈ

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារក្ដីលោក នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក សួន វិសាល

**មេធាវីការពារក្ដីលោក ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គីមសួន

លោក ម៉ែហេស រ៉ៃ *(Mr. Mahesh RAI)*

លោក យីគាំង លូ *(Mr. Yiqiang LIU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វែនស៍ | អង់គ្លេស |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក នីកូឡាស កូមជែន | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក សេង លាង | ខ្មែរ |
| លោក សួន វិសាល | ខ្មែរ |
| កញ្ញា អង់តា ហ្គេសសេ | បារាំង |
| លោក ខៀវ សំផន | ខ្មែរ |
| លោក យីគាំង លូ | អង់គ្លេស |
| លោក មាស សុខា (2-TCW-936) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក មាស សុខា** (2-TCW-936)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ..........ទំព័រ ២២

សួរដោយលោក សេង លាង ផ្តើមពី ..........ទំព័រ ២៩

សួរដោយលោក ឌេល លីសាក់ ផ្តើមពី ..........ទំព័រ ៤៣

# កិច្ចដំណើរការនីតិវិធី

[០៩:០១:២៩]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

ថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានសមាសភាពចៅក្រមដូចខាងក្រោមនេះ៖ ១) គឺរូបយើង និល ណុន ជាប្រធាន ២) ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ៣) ចៅក្រម យ៉ា សុខន ៤) លោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ៥) លោកចៅក្រម យូរខត្តរា។ និងមានចៅក្រមបម្រុងចំនួនពីររូប ១) គឺលោចៅក្រម ធូនមណី ២) គឺលោកចៅក្រម ម៉ាទីន ខារ៉ុបគីន។ នៅថ្ងៃនេះ ចៅក្រម ម៉ាទីន ខារ៉ុបគីន មានធុរៈ គាត់មិនអាចចូលរួមនៅក្នុងដំណើរការសវនាការបាននៅព្រឹកនេះ។

អង្គជំនុំជម្រះសាលាដំបូងសូមរំឭកដោយសង្ខេប អំពីប្រវត្តិនីតិវិធីដែលនាំឲ្យមានសវនាការនៅក្នុងថ្ងៃនេះ។ សវនាការលើអង្គសេចក្តីនៃសំណុំរឿង០០២/០២ ពីដំបូងបានគ្រោងចាប់ផ្តើមធ្វើនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤។ ទោះជាយ៉ាងនេះក្តីក៏មេធាវីការពារក្តី ខៀវ សំផន បានប្រកាសថា ពួកគេនឹងមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២នេះ រហូតក្រោយពេលពួកគេដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១ រួចរាល់ជាមុនសិន។

[០៩:០៣:៥០]

អង្គជំនុំជម្រះសាលាដំបូងបានព្យាយាមចាប់ផ្តើមសវនាការនៅថ្ងៃទី១៧ និង ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ប៉ុន្តែសហមេធាវីជាតិ និង សហមេធាវីអន្តរជាតិរបស់ ខៀវ សំផន មិនបានបង្ហាញខ្លួននៅក្នុងបន្ទប់សវនាការក្នុងថ្ងៃទាំងពីរនេះឡើយ។ ក្រោយពេលព្យាយាមពុំបានសម្រេចជាច្រើនលើកច្រើនសាដើម្បីស្វែងរកការសម្របសម្រួលដែលអាចធ្វើទៅមុខទៅបានជាមួយនឹងមេធាវីការពារក្តី ខៀវ សំផន ដើម្បីអាចឲ្យសវនាការនៅក្នុងសំណុំរឿង០០២/០២ អាចចាប់ផ្តើមបាននោះ អង្គជំនុំជម្រះសាលាដំបូងគ្មានជម្រើសអ្វីក្រៅពីពន្យារពេលធ្វើសវនាការរហូតដល់មកថ្ងៃនេះ គឺថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥។ សេចក្តីសម្រេចនេះបានធ្វើឡើង ដោយបានផ្អែកមួយផ្នែកទៅលើសេចក្តីប្រកាសរបស់មេធាវីការពារក្តី ខៀវ សំផន ដែលថាពួកគេនឹងមានលទ្ធភាពត្រឡប់មកចូលរួមនៅក្នុងសវនាការក្នុងសំណុំរឿង០០២/០២

វិញបាន ដរាបណាពួកគេបានដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ រួចរាល់សិន។ ថ្ងៃធ្វើសវនាការចំនួន ២៥ថ្ងៃ ក្នុងរយៈពេល១០សប្តាហ៍ត្រូវខាតបង់គួរឲ្យសោកស្តាយ។

នៅក្នុងអំឡុងពេលនេះ អង្គជំនុំជម្រះបានចាត់វិធានការមួយចំនួនដើម្បីដោះស្រាយការប្រព្រឹត្តរបស់មេធាវីជាតិ និងមេធាវីអន្តរជាតិការពារក្តី ខៀវ សំផន ដើម្បីកុំឲ្យកិច្ចដំណើរការនីតិវិធីសវនាការមានការរាំងស្ទះនាពេលអនាគត និងដើម្បីឲ្យសំណុំរឿង០០២/០២ ដំណើរការទៅមុខប្រកបដោយយុត្តិធម៌និងឆាប់រហ័សនោះ កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ អង្គជំនុំជម្រះបានបង្គាប់ឲ្យអង្គភាពគាំពារការពារក្តីតែងតាំងមេធាវីជាតិ និង មេធាវីអន្តរជាតិប្រចាំការដែលជាមេធាវីតែងតាំងដោយតុលាការ។ មេធាវីប្រចាំការមានតួនាទីរៀបចំ និង ត្រៀមខ្លួនទទួលការការពារក្តីឲ្យ ខៀវ សំផន នៅក្នុងពេលណាមួយដែលអង្គជំនុំជម្រះយល់ឃើញថា ចាំបាច់ដើម្បីជំនួសមេធាវីបច្ចុប្បន្នរបស់ ខៀវ សំផន។

អង្គជំនុំជម្រះកត់សម្គាល់ឃើញថានៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៥ អង្គភាពគាំពារការពារក្តីបានចាត់តាំងលោកស្រី ទូច វរល័ក្ស និងលោក ខលវីន សោនដឺស៍ *(Mr.Calvin SAUNDERS)* ជាមេធាវីប្រចាំការជាតិនិងអន្តរជាតិ។ វិធីធ្វើសម្បថសម្រាប់មេធាវីអន្តរជាតិប្រចាំការ បានធ្វើរួចរាល់ហើយនៅថ្ងៃទី០៥ ខែមករា ឆ្នាំ ២០១៥។

[០៩:០៦:៥២]

អង្គជំនុំជម្រះសាលាដំបូងសូមរំឭកឡើងវិញថា នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងក៏បានចេញដីកាសម្រេចបញ្ជូនកំហុសវិជ្ជាជីវៈមេធាវីជាតិ និង អន្តរជាតិរបស់ ខៀវ សំផន ទៅស្ថាប័នគណៈមេធាវីរបស់ពួកគេរៀងៗខ្លួនដោយអនុលោមតាមវិធាន៣៨ អនុវិធានពីរ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ក្នុងគោលបំណងជូនដំណឹងទៅក្រុមប្រឹក្សាវិន័យរបស់ស្ថាប័នទាំងនេះ។ អង្គជំនុំជម្រះសាលាដំបូងសូមកត់សម្គាល់ផងដែរថា នៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចរក្សាថ្ងៃធ្វើសវនាការបីថ្ងៃ ក្នុងមួយសប្តាហ៍ដែលរហូតដល់ពេលការវាយតម្លៃជាថ្មីមួយលើសម្បទារបស់ជនជាប់ចោទនៅក្នុងការចូលរួមសវនាការបានចប់សព្វគ្រប់។ ការវាយតម្លៃនេះ គ្រោងនឹងធ្វើឡើងនៅក្នុងអំឡុងថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ ខាងមុខនេះ។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តភាពភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះ និងអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅក្នុង

ថ្ងៃនេះ។

[០៩:០៨:១៧]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! នៅក្នុងសវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ កត់សម្គាល់ផងដែរ ពីវត្តមានលោកស្រី ទូច វរល័ក្ស និងលោក ខលវីន សោនដឺស៍ ដែលជាមេធាវីប្រចាំការជាតិ និងអន្តរជាតិ តែងតាំងដោយអង្គជំនុំជម្រះសម្រាប់លោក ខៀវ សំផន។ ចំណែកឯសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះគឺសាក្សីដែលមានរហស្ស-នាម 2-TCW-936។ សាក្សីរូបនេះមានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្ប-វេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង០០២នេះទេ។ ហើយគាត់បានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែក កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤។ សាក្សីរូបនេះ មិនមានមេធាវីប្រឹក្សានោះទេ។ នៅថ្ងៃនេះដែរ យើងមានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូបដែលមានរហស្ស-នាម 2-TCCP-296 ដើមបណ្តឹងរូបនេះមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះផងដែរ។ សូមអរគុណលោកប្រធាន។

[០៩:០៩:៣៥]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកស្រី សែ កុលវុឌ្ឍី។

ឥឡូវនេះ ខ្ញុំប្រកាសធ្វើសវនាការពិភាក្សាដេញដោល លើភស្តុតាងលើសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះសូមជម្រាបដល់ភាគី និងសាធារណជនបានជ្រាបថា--

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរដល់អស់លោក លោកស្រីទាំងអស់ដែលមានវត្តមាននៅទីនេះ។ ខ្ញុំគិតថា ដោយមានបញ្ហារៀបចំនៅព្រឹកនេះ គឺយើងគួរតែឡើងនិយាយដោយខ្លីទេ។ ខ្ញុំបានឮពីការនិយាយរំឭកនីតិវិធីដោយលោកប្រធាន។ យើងមានវត្តមាននៅទីនេះហើយ ដូចដែលយើង

បានជម្រាបជូនថានៅពេលដែលសិទ្ធិរបស់លោក ខៀវ សំផន ត្រូវបានគោរពនៅក្នុងការបណ្ដឹងឧទ្ធរណ៍ មិនមានបញ្ហាអីទេ ដែលក្រុម ខៀវ សំផន មានវត្តមាននៅទីនេះ។ ខ្ញុំឃើញថាអង្គជំនុំជម្រះបានជ្រើសរើសមេធាវីប្រចាំនៅទីនេះ។ ខ្ញុំមានការភ្ញាក់ផ្អើលណាស់ដែលថា អង្គជំនុំជម្រះបានដាក់កំហិតឲ្យមានមេធាវីទាំងអស់នេះនៅទីនេះ ខ្ញុំ -- នៅ -- និយាយជាលក្ខណៈបុគ្គល គេដាក់ឲ្យបង្ខំឲ្យមានវត្តមានរបស់មេធាវីទាំងអស់នេះ ដែលត្រូវបានជ្រើសតាំងដោយអង្គជំនុំជម្រះ។ ក៏ប៉ុន្តែឥឡូវនេះមិនទាន់មានតួនាទីតាមនីតិវិធីដែលថា ពីព្រោះថាលោក ខៀវ សំផន ត្រូវមានមេធាវីរបស់គាត់ដែលតំណាងឲ្យគាត់ហើយដែលមេធាវីជ្រើសរើសដោយគាត់ផ្ទាល់ ហើយដែលគាត់ធ្វើការដើម្បីផលប្រយោជន៍របស់លោក ខៀវ សំផន នេះតែម្ដង។ ដូច្នេះមេធាវីប្រចាំដែលមានវត្តមាននៅទីនេះ គឺថាយើង -- អ៊ីចឹងយើងអង្គុយប្រជ្រៀតគ្នា ដោយសារមនុស្សច្រើន ហើយយើងមិនអាចមានសម្ភារៈគ្រប់គ្រាន់ដើម្បីធ្វើការទេ ដោយខុសកន្លែង។ អ៊ីចឹងមេធាវីប្រចាំនេះ ដែលមានវត្តមាននៅទីនេះ មិនមែនថាដោយសារ -- អង្គជំនុំជម្រះភ័យខ្លាចថាលោក ខៀវ សំផន មិនមានអ្នកតំណាង ប៉ុន្តែការពិតលោក ខៀវ សំផន មានអ្នកតំណាងហើយៗ។

[០៩:១២:០៥]

ខ្ញុំសូមលើកនូវការប្រៀបធៀបមួយ។ នៅពេលដែលយើងមានអ្នកជំនួសនៅកន្លែងណាមួយនោះ បើយើងកីឡាបាត់ទាល់អីហ្នឹង គឺថាអ្នកជំនួសគឺគេអង្គុយនៅក្រៅទេ គេមិនដែលអង្គុយនៅកន្លែងជាមួយគ្នាទេ។ ដូច្នេះ បើថា បើយើងគិតអំពីគោលការណ៍រក្សាការសម្ងាត់អីជាដើមនោះ យើងនៅខាងការពារក្ដីនេះ ជួនកាលយើងមានទំនាក់ទំនងជាមួយមេធាវីផ្សេងទៀត ជាមួយកូនក្ដីរបស់ខ្លួនយើងផ្ទាល់ផង។ អ៊ីចឹង មូលហេតុនៃមេធាវីទាំងអស់នេះ ខ្ញុំមិនមែននិយាយថាគាត់មិនមានអាជីពអីនោះ លក្ខណៈអាជីពនោះទេ ប៉ុន្តែខ្ញុំចង់និយាយថា វត្តមានរបស់គាត់នោះមិនមានការចាំបាច់ ហើយនិងជាកាតព្វកិច្ចនោះទេ ហើយបើសិនជាអង្គជំនុំជម្រះចង់ឲ្យលោក ខៀវ សំផន ត្រូវបានតំណាងដោយនិរន្តភាព ហើយកុំឲ្យមានគ្រោះថ្នាក់នោះ បើសិនជាផ្ដល់វត្តមានមេធាវីប្រចាំនោះនៅទីនេះ គិតថាមាននិរន្តភាពក្នុងការតំណាងឲ្យលោក ខៀវ សំផន ប្រយោជន៍លោក ខៀវ សំផន ហ្នឹង ខ្ញុំគិតថាគាត់អាចប្រតិចារិកបានតើ មិនចាំបាច់មកទីនេះទេ។ អ៊ីចឹង គ្រាន់អានេះគ្រាន់តែជាការដាក់សម្ពាធដល់ក្រុមមេធាវីរបស់លោក ខៀវ សំផន ឬលោក ខៀវ សំផន ប៉ុណ្ណោះទេ។ ដូច្នេះ អង្គជំនុំជម្រះមិនគោរពដល់គោលជំហររបស់លោក ខៀវ សំផន ទេ គោលជំហរឯករាជ្យ។ ក៏ប៉ុន្តែទោះបីយ៉ាងណាក្ដីវត្តមានរបស់មេធាវីប្រចាំនេះមិនជា

ផលប្រយោជន៍ដល់រូបលោក ខៀវ សំផន ទេ។

បើសិនជាអង្គជំនុំជម្រះយល់ឃើញថា វត្តមានរបស់គាត់ជាប្រចាំនៅទីនេះនេះ អ៊ីចឹង ឃើញថា -- យើងឃើញថាគាត់ហ្នឹងកំពុងតែអង្គុយនៅកន្លែងក្រុមមេធាវីរបស់លោក នួន ជា ហើយៗ យើងប្រជ្រៀតគ្នានៅអង្គុយនៅទីនេះ។

ខ្ញុំសូមនិយាយជាផ្លូវការនៅទីនេះ នេះគឺគ្រាន់តែសារមួយដ៏កំសត់ទេ ដែលអង្គជំនុំជម្រះបានផ្តល់ទៅខាងការពារក្តីដែលនិយាយប្រាប់អំពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយនិយាយអំពីការធានាដល់ -- ការជម្រះសេចក្តីប្រកបដោយយុត្តិធម៌ហើយ។ ដូច្នេះ អ៊ីចឹងឃើញថាមានសម្ពាធហើយ តួនាទីរបស់មេធាវីការពារក្តីមិនមែនថាធ្វើឲ្យកាត់ទោសជនជាប់ចោទយ៉ាងស្រួល ហើយមិនមានការកាត់ក្តីដោយយុត្តិធម៌ទេ យើងត្រូវធ្វើការដោយគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់យើង ហើយអង្គជំនុំជម្រះបានបញ្ជាក់អំពីពាក្យបណ្តឹងចុះនៅថ្ងៃទី០៦ ខែ០១ ឆ្នាំ២០១៥ ហើយយើងខាងមេធាវី យើងខំរៀបចំខ្លួនដើម្បីដឹងថាយើងត្រូវការពារកូនក្តីយ៉ាងម៉េច ព្រោះថាយើងមានការចោទប្រកាន់ពីអង្គជំនុំជម្រះអំពីការ -- អត្តចរិតមិនល្អរបស់យើង ឬក៏យើងបំពេញការងារមិនល្អ។ អ៊ីចឹង ខ្ញុំឃើញថាការចោទប្រកាន់នេះ វាគួរឲ្យសោកស្តាយណាស់ ខ្ញុំមិនដឹងថាមានការចោទប្រកាន់មកខាងភាគីការពារក្តីយើង។ អ៊ីចឹងខ្ញុំ ថាយើងហ្នឹងខុសក្រមសីលធម៌វិជ្ជាជីវៈ ហើយលោក គង់ សំអុន ក៏នៅទីនេះផងដែរ។ គាត់ក៏ថាបានដែរ ថាគាត់ធ្វើការងារនៅទីនេះ តែងតែគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ដើម្បីការពារផលប្រយោជន៍កូនក្តីរបស់យើងឲ្យបានល្អ។ ខ្ញុំសោកស្តាយណាស់ដែលអង្គជំនុំជម្រះមើលឃើញខុសពីនេះ គឺថាមានការសំខាន់ -- ជាការសំខាន់ណាស់ដែលត្រូវឲ្យមានអង្គភាពណាមួយនិយាយបំភ្លឺអំពីការគោរពក្រមសីលធម៌វិជ្ជាជីវៈនេះ។

[០៩:១៦:០៩]

ខ្ញុំមិនអាចនិយាយឲ្យវែងលើសពីហ្នឹងទៀតទេ ខ្លាចគេថាខ្ញុំហ្នឹងអូសបន្លាយពេលវេលា។ ខ្ញុំគ្រាន់តែចង់និយាយថា ជាការអាក្រក់មួយដែលដាក់សម្ពាធទៅលើលោក ខៀវ សំផន ហើយនិងមេធាវីរបស់លោក ខៀវ សំផន ពីព្រោះថាក្នុងឋានៈយើងជាមេធាវីនៅទីនេះ យើងមិនដឹងថាឆ្លើយយ៉ាងម៉េចទៅនឹងសម្ពាធនោះទេ យើងចង់បន្តការពារកូនក្តីរបស់យើងដោយសេរីភាព រហូតដល់ពេលណាដែលគេដកយើងចេញពីទីនេះ។ ទោះបីជាគោលបំណងរបស់អង្គជំនុំជម្រះយ៉ាងណាក៏ដោយ ហើយយើងខ្ញុំសូមរំឭកថា យើងធ្វើការនៅទីនេះតែងតែគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់យើង។ ហើយទោះយ៉ាងណាក្តី

បើរឿងហ្នឹង មានរឿងយ៉ាងណាកើតឡើងក្តី គឺថាខណៈមេធាវីរបស់យើងនឹងធ្វើការបំភ្លឺ ខ្ញុំគិតថា បើសិនជាអង្គជំនុំជម្រះយល់ឃើញថា ត្រូវឱ្យមេធាវីនេះប្រចាំនេះធ្វើការក្នុងពេលជាមួយគ្នាជាមួយយើង ខ្ញុំគិតថាប្រហែលជាមិនមានប្រយោជន៍អ្វីទេ ក៏ប៉ុន្តែអានេះជាការសម្រេចរបស់អង្គជំនុំជម្រះ ក៏ប៉ុន្តែការបង្ខំឱ្យមកអង្គុយនៅទីនេះ ហើយមិនមានសិទ្ធិឡើងនិយាយអ្វីនោះ គឺថាមើលទៅគ្រាន់តែជាសារមួយដែល -- ជាសារមួយដ៏អវិជ្ជមានដែលអង្គជំនុំជម្រះបានផ្តល់មកខាងការពារក្តី--

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីសុំសង្ខេបខ្លីបានហើយ។ មេធាវីបានបញ្ជាក់ហើយអំមិញថា ខ្លួនគឺបានគិតថា មិនចង់ឱ្យសាធារណជន ឬក៏ភាគីដទៃថា លោកស្រីការពារដោយអូសពេលវេលានោះទេ។ លោកស្រីបាននិយាយម្តងហើយម្តងទៀត បីដង បួនដងទៅហើយ។ សូមលោកស្រីនិយាយសង្ខេបដើម្បីឱ្យយើងជាអង្គជំនុំជម្រះ និងភាគីដទៃទៀត និងសាធារណជនបានយល់ បានហើយលើកបញ្ហានេះ ព្រោះយើងបានចេញលិខិត ចេញដីកាសម្រេចរួចអស់ហើយ ជាលាយលក្ខណ៍អក្សរ។

ហើយពេលនិយាយសុំពិចារណាឡើងវិញ រំឭកថា គោរពអ្នកបកប្រែភាសាផង។ និយាយឱ្យបានយឺតៗដើម្បីអ្នកបកប្រែមានសមត្ថភាព និងលទ្ធភាពអាចស្តាប់ និងបកប្រែបានពេញលេញតាមខ្លឹមសារដែលលោកស្រីមានប្រសាសន៍ផង។

[០៩:១៨:៥១]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំនឹងមិននិយាយវែងឆ្ងាយទៀតទេ ខ្ញុំគ្រាន់តែចង់និយាយថា យើងនៅតែបន្តការពារលោក ខៀវ សំផន ដោយឯករាជ្យ ហើយនិងដោយសេរីភាព។ នេះគឺជាអ្វីដែលខ្ញុំចង់គូសបញ្ជាក់តាំងពីដើមពេលសវនាការនេះ ដោយសុំឱ្យអង្គជំនុំជម្រះថា សុំឱ្យគិតពិចារណាឡើងវិញពីសេចក្តីសម្រេចដាក់ឱ្យមេធាវីប្រចាំនេះមានវត្តមាននៅទីនេះ ពីព្រោះថាពួកគាត់ពុំមានតួនាទីផ្នែកនីតិវិធីអីទេក្នុងការជម្រះសេចក្តីនេះ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។

សូមអញ្ជើញលោក គង់ សំអុន! ខ្លីៗបានហើយ ព្រោះឯកសារមានសរសេរសព្វគ្រប់ហើយ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ លោក លោកស្រីចៅក្រម និងភាគីទាំងអស់ សាធារណជនដែលមានវត្តមាននៅទីនេះ និងអ្នកតាមដានតាមទីកន្លែងផ្សេងទៀតផងដែរ។

ជាបឋមខ្ញុំបាទសុំធ្វើការកត់សម្គាល់ទាក់ទងទៅនឹងវត្តមានមេធាវីប្រចាំការ ដែលតាមការចាត់តាំងរបស់អង្គជំនុំជម្រះនៅពេលនេះ។

បញ្ហាសម្រាប់ថាការពារសិទ្ធិរបស់លោក ខៀវ សំផន ដែលអង្គជំនុំជម្រះមានបំណងធានានូវមេធាវីសម្រាប់ការពារលោក ខៀវ សំផន។ ចំណុចនេះ ខ្ញុំបាទយល់ឃើញថាជាចំណុចល្អរបស់អង្គជំនុំជម្រះ ក៏ប៉ុន្តែចំណុចដែលអវិជ្ជមានដែលយើងគួរពិនិត្យវិញនោះគឺថា មេធាវីដែលការពារលោក ខៀវ សំផន ត្រូវតែប្រកបដោយគុណភាព ទើបវាមានប្រសិទ្ធភាពក្នុងការការពារ។ មានន័យថាការសហការរបស់លោក ខៀវ សំផន ជាមួយនឹងក្រុមមេធាវីរបស់គាត់ ដោយធ្វើការដោយៗពេញលេញ ពេញដៃពេញជើង។ ក៏ប៉ុន្តែចំពោះចំណាត់តាំងរបស់មេធាវីប្រចាំការនេះមានលក្ខណៈផ្ទុយពីជំហរវិជ្ជាជីវៈមេធាវីជាពិសេសទាក់ទងនឹងឯករាជ្យភាពរបស់មេធាវីជាដើម ដែលក្រុមមេធាវីប្រចាំការនេះត្រូវធ្វើតាមការណែនាំរបស់អង្គជំនុំជម្រះ។ បញ្ហានេះ វាអាចចោទជាសំណួរតទៅទៀត ថាតើបញ្ហារបស់ពួកយើងដែលអង្គជំនុំជម្រះបាន ដូចបានជម្រាបអម្បាញ់មិញថា កំពុងបានរៀបចំពាក្យទៅក្រុមគណៈមេធាវីឬក៏អង្គការរបស់មេធាវីដែលមានភារកិច្ចត្រួតពិនិត្យទៅលើវិន័យរបស់ពួកយើងជាដើម។ បញ្ហាត្រង់ថារហូតមកដល់ពេលនេះស្ថាប័នមានសមត្ថកិច្ចទាំងនោះមិនទាន់ធ្វើសេចក្ដីសម្រេចថាយើងបានធ្វើខុសនឹងវិជ្ជាជិវៈរបស់យើងទេ។ ហើយអ្វីដែលជាចំណាត់ការរបស់អង្គជំនុំជម្រះនេះ គឺជាការយល់ឃើញរបស់អង្គជំនុំជម្រះថាពួកយើងបានធ្វើខុសនឹងវិជ្ជាជីវៈ។ បញ្ហានេះ វាធ្វើឲ្យមានការប៉ះពាល់ទៅដល់ការអនុវត្តនូវសិទ្ធិក្នុងការការពារប្រកបដោយប្រសិទ្ធភាពរបស់លោក ខៀវ សំផន ដោយហេតុថាវត្តមានរបស់មេធាវីប្រចាំការនៅពេលនេះ អាចធ្វើឲ្យមានការរំខានទៅលើការការពារលោកផងដែរ។

[០៩:២២:២៦]

ទាក់ទងទៅនឹងបញ្ហាដាក់វិន័យ។ ក្នុងករណីដែលក្រុមប្រឹក្សាគណៈមេធាវី ក្នុងករណីប្រទេសកម្ពុជាយើង ជាពិសេសទាក់ទងនឹងករណីរបស់ខ្ញុំផ្ទាល់។ បើសិនជាក្រុមប្រឹក្សាគណៈមេធាវី ក្រុមប្រឹក្សាមិនបានរកឃើញថាខ្ញុំបានប្រព្រឹត្តនូវកំហុសវិជ្ជាជីវៈទេ អ៊ីចឹងសួរថាតើមានបញ្ហាអ្វីទាក់ទងទៅនឹងការចាត់តាំងមេធាវីជំនួស មេធាវីប្រចាំការនេះ? វាអាចមើលឃើញថា វាជាចំណុចមួយធ្វើការគាបសង្កត់

ទៅលើការអនុវត្តក្នុងការការពាររបស់មេធាវីរបស់លោក ខៀវ សំផន ជាមិនខាន។ វាមិនមែនដើម្បីធានាថា លោក ខៀវ សំផន ត្រូវទទួលបាននូវសិទ្ធិមានមេធាវីនោះទេ។ ដោយហេតុថា លោក ខៀវ សំផន គាត់បានបញ្ជាក់រួចហើយ គាត់បានពេញចិត្តចំពោះមេធាវីដែលកំពុងការពាររបស់គាត់។

ចំពោះទណ្ឌកម្ម។ ឧទាហរណ៍ថាក្រុមប្រឹក្សាគណៈមេធាវីរកឃើញថា មានកំហុស ខ្ញុំអាចត្រូវបានគេដាក់វិន័យដោយការព្រមាន ដោយការព្រមានជាលាយលក្ខណ៍អក្សរ និងដោយការព្យួរ ឬដោយការលុបឈ្មោះចេញពីបញ្ជី។ យើងអត់ដឹងថា វិន័យដែលក្រុមប្រឹក្សាគណៈមេធាវីនឹងដាក់នោះជាវិន័យបែបណាទេ។ បញ្ហានេះជាចំណោទមួយ ដែលថាបើសិនជាក្នុងករណីក្រុមប្រឹក្សាគណៈមេធាវីដាក់វិន័យជាការព្រមាន ដូច្នេះវាមិនមានអីប៉ះពាល់ដល់ការអនុវត្តវិជ្ជាជីវៈរបស់យើងទេ យើងនៅតែអាចការពារកូនក្តីរបស់យើងនៅតាមតុលាការបានជាដរាប លើកលែងតែករណីព្យួរវិជ្ជាជីវៈ ឬក៏បណ្តេញ លុបឈ្មោះចេញពីបញ្ជីរបស់គណៈមេធាវី។ ដូច្នេះ ខ្ញុំសូមឱ្យតុលាការមេត្តាពិនិត្យពិចារណាលើសេចក្តីសម្រេចរបស់ខ្លួន ទាក់ទងទៅនឹងចំណាត់ការនៃការចាត់តាំងមេធាវីប្រចាំការនេះ ដែលអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិការការពាររបស់មេធាវី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

[០៩:២៤:៣១]

**លោក សួន វិសាល៖**

សូមគោរពលោកប្រធាន ខ្ញុំបាទមិនមានចំណុចអីវែងឆ្ងាយទេ ប៉ុន្តែគ្រាន់ថាខ្ញុំចង់ចូលរួមទស្សនៈច្បាប់ពីរចំណុច។ គឺថាទី១ ទាក់ទងតួនាទីរបស់មេធាវីប្រចាំការ។ គឺថាមកដល់ពេលនេះ តើគាត់ជាមេធាវីការពារក្តី ឬក៏មេធាវីប្រចាំការ? កាលណាយើងមិនទាន់ក្លាយជាមេធាវីការពារក្តីឱ្យជនជាប់ចោទទេ គឺថាតួនាទីរបស់យើង គឺថាមិនអាចដូចមេធាវីដែលគេការពារក្តីទេ។ អ៊ីចឹង សូមលោកប្រធានពិចារណាវិញអំពីតួនាទីរបស់គាត់ឱ្យបានច្បាស់លាស់។ អានេះចំណុចទី១។ ចំណុចទី២ ការវត្តមានរបស់គាត់។ កាលណានៅពេលដែលតួនាទីរបស់គាត់មិនទាន់ក្លាយជាអ្នកការពារ អ៊ីចឹងគាត់មិនអាចមកអង្គុយជាមួយក្នុងក្រុមការពារបានទេ។ នេះជាទស្សនៈដែលយើងត្រូវការពារ ត្រូវពិចារណាឡើងវិញ។

អ៊ីចឹងនៅពេលដែលគាត់នៅពេលបម្រុងអ៊ីចឹង ហើយធ្វើឱ្យគាត់អង្គុយក្បែរយើងអ៊ីចេះ សាធារណជនអាចច្រឡំថា ហ្អេ! គាត់ជាមេធាវីការពារដែរ។ តាមពិតគឺគាត់មិនមានមេធាវីការពារទេ គាត់គ្រាន់

តែជាបម្រុងដែលតុលាការចាត់ចែង ហើយគាត់មិនទាន់បានកូនក្ដីពឹងនៅឡើយ។ ដូច្នេះសិទ្ធិរបស់គាត់ក្នុងការការពារក្ដីមិនទាន់មានទាល់តែសោះ។ នេះជាចំណុចច្បាប់ដែលមានចែងនៅក្នុងច្បាប់របស់យើងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ហើយចំណុចមួយទៀតប្រសិនបើយើងអង្គុយចូលគ្នាអ៊ីចេះ គឺថានៅពេលយើងពិភាក្សារការពារក្ដី គឺថាយើងអាចបាត់បង់ការសម្ងាត់របស់ក្រុមមួយៗ ធ្វើឲ្យអារម្មណ៍របស់ក្រុមរបស់យើងការពារក្ដីរបស់យើងគឺថាមានការភ័យខ្លាច។ អូ៎! តិចអ្វីដែលយើងពិភាក្សាគ្នា អាចគាត់ឮអាចគាត់ដឹង។ អ៊ីចឹងអាចធ្វើឲ្យប៉ះពាល់ដល់ការការពាររបស់យើង។

ដូច្នេះសូមលោកប្រធាន និងអង្គជំនុំជម្រះពិចារណាឡើងវិញអំពីចំណុចទាំងអស់នេះ។ បាទសូមអរគុណ។

[០៩:២៦:៤២]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ សូមគោរពសហភាតាទាំងអស់។

លោកប្រធានខ្ញុំចង់សុំមានយោបល់ថា ខ្ញុំបានទទួលលិខិតពីម្សិលមិញពាក់ព័ន្ធទៅនឹងការរៀបចំកន្លែងអង្គុយហ្នឹង គឺខ្ញុំមានការភ្ញាក់ផ្អើលណាស់ ពីព្រោះថាយើងមិនដឹងថាអ្នកណាត្រូវអង្គុយនៅត្រង់កន្លែងណា។ ដូច្នេះខ្ញុំសូមឲ្យពិចារណាអំពីបញ្ហានេះ។

បញ្ហាដែលមេធាវីប្រចាំការរបស់មេធាវី ខៀវ សំផន អង្គុយនៅជួរមុខរបស់មេធាវីការពារក្ដីជាពិសេសគឺរបស់ក្រុមយើងខ្ញុំតែម្ដង។ ខ្ញុំយល់ឃើញថា ការធ្វើបែបនេះគឺហាក់បីដូចជាការធ្វើ មានការបន្ទុះបង្អាប់មកដល់ក្រុមយើងខ្ញុំ ក៏ដូចជាក្រុម ខៀវ សំផន។ ខ្ញុំមិនយល់ថាហេតុអ្វីបានជាចាត់ទុកថាក្រុមមេធាវីការពារក្ដី ខៀវ សំផន ហាក់មិនមានសិទ្ធិស្មើគ្នាទៅនឹងក្រុមមេធាវីប្រចាំការបែបនេះទៅវិញនោះ? ហេតុអ្វីក៏ក្រុមមេធាវីប្រចាំការមកអង្គុយនៅទីនេះ។ គាត់នឹងមិនត្រូវឡើងនិយាយតតាំងនៅក្នុងសវនាការនេះទេ។ បើសិនណាជាយ៉ាងដូច្នេះទេ អាចឲ្យគាត់អង្គុយនៅចំហៀងណាមួយនៃអាសនៈរបស់ -- នៅខាងៗ ជ្រុងម្ខាងវិញជាការប្រសើរជាជាង។ មិនមានជាជួរកៅអីណាមួយដែលគួរណាទុកឲ្យមេធាវីប្រចាំការអង្គុយបែបនេះទេ។ ដូច្នេះយើងខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាពិចារណា អាចដាក់គាត់ទៅជួរខាងក្រោយខ្នងរបស់ក្រុមយើងខ្ញុំ ឬក៏អាចឲ្យនៅខាងក្រៅបន្ទប់សវនាការតែម្ដង។ សូមអរគុណ។

[០៩:២៨:៣៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ខៀវ សំផន!

**លោក ខៀវ សំផន៖**

សូមអរគុណលោកប្រធាន។ សូមអស់លោក លោកស្រីចៅក្រម, អស់លោក លោកស្រីទាំងអស់ដែលមានមុខនៅទីនេះ! ព្រះសង្ឃគ្រប់ព្រះអង្គនៅតាមវត្តអារាមនានាទូទាំងប្រទេស។ បងប្អូនរួមជាតិជាទីគោរពស្នេហា។

ដូចព្រះសង្ឃ ដូចបងប្អូនរួមជាតិបានជ្រាបហើយ ថាខ្ញុំត្រូវមានសិទ្ធិទទួលការកាត់ទោសពីតុលាការមួយដែលមិនលម្អៀង ដោយមានមេធាវីការពារក្ដីដែលខ្ញុំបានជ្រើសរើសដោយខ្លួនខ្ញុំ។ ឥឡូវនេះព្រះអង្គ បងប្អូនរួមជាតិឃើញអី។ ទី១ ខ្ញុំសូមបញ្ជាក់ឡើងវិញថា ខ្ញុំមានការទុកចិត្តលើមេធាវីរបស់ខ្ញុំទាំងបីរូប គឺលោក អាកទួរ វែកគែន, អ្នកស្រី អង់តា ហ្គីសសេ ដែលជាមេធាវីអន្តរជាតិ ហើយលោក គង់ សំអុន ដែលជាមេធាវីជាតិរបស់ខ្ញុំ។ ខ្ញុំកាន់តែស្គាល់គាត់ ខ្ញុំកាន់តែទុកចិត្តលើគាត់។ យើងបានរួមគ្នាធ្វើសារណាបណ្ដឹងឧទ្ធរណ៍មួយដែលខ្ញុំយល់ឃើញថាល្អ ណែន ទាំងខាងផ្លូវច្បាប់ ទាំងខាងផ្លូវអង្គហេតុ។ ហើយដែលយើងទើបនឹងធ្វើបានហើយ ចប់សព្វគ្រប់យកទៅដាក់កាលពីថ្ងៃទី២៩ ធ្នូ កន្លងទៅនេះ។ សារណានេះបានចង្អុលចំៗ ច្បាស់ៗ នូវការខុសឆ្គងរបស់អង្គជំនុំជម្រះសាលាដំបូង។

សរុបមួយម៉ាត់ទៅមេធាវីខ្ញុំទាំងបីរូបគាត់បានបង្ហាញច្បាស់ ឲ្យខ្ញុំពេញចិត្ត ឲ្យខ្ញុំឃើញថាគាត់ជាមេធាវីឯករាជ្យ មិនរណបតុលាការ។ តែព្រឹកនេះអង្គជំនុំជម្រះបែរជាចាត់តាំង ស្អីមេធាវីបម្រុងស្អីខ្ញុំយល់ឃើញថានេះជាល្បិច ជាស្នៀតដើម្បីរារាំងមិនឲ្យមេធាវីរបស់ខ្ញុំបំពេញភារកិច្ចរបស់គាត់បានល្អត្រឹមត្រូវចប់ចុងចប់ដើមតទៅទៀត ដើម្បីតុលាការអង្គជំនុំជម្រះសាលាដំបូង ចាត់ចែងអ្វីៗស្រេចតែចិត្តធ្វើតាមចិត្តចង់ រំលោភច្បាប់ បំពានលើច្បាប់យ៉ាងម៉េចស្រេចតែខ្លួនធ្វើបាន។ អានេះ ខ្ញុំសូមបងប្អូនរួមជាតិ ព្រះអង្គគ្រប់ព្រះអង្គសូមជួយវិនិច្ឆ័យផងចុះ! សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ភាគីដទៃទៀតមាន -- ចង់មានមតិយោបល់អ្វីទេពាក់ព័ន្ធនឹងបញ្ហានេះ?

សូមអញ្ជើញខាងសហព្រះរាជអាជ្ញា!

[០៩:៣២:៤៦]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមមានយោបល់សង្ខេប។ ហេតុផលដែលយើងកំពុងតែពិភាក្សាអំពីមេធាវីប្រចាំការនេះគឺដោយសារថានៅថ្ងៃទី១៧ ខែតុលា មេធាវីការពារក្ដីក្នុងរឿងក្ដីនេះ បានដើរចេញពីបន្ទប់សវនាការ ហើយយើងបាត់បង់ពេលវេលាជំនុំជម្រះរហូតដល់ពីរខែ។ ដូច្នេះ យើងរង់ចាំការសួរសក្ខីកម្មសាក្សី រង់ចាំរយៈពេលពីរខែ វាមានការបាត់បង់ថវិការតុលាការយ៉ាងច្រើន ហើយពេលវេលាក៏អូសបន្លាយរហូតទៅដល់ពីរខែ។ មេធាវីប្រចាំការនៅតុលាការអន្តរជាតិ ក៏ជានៅតុលាការជាតិ គឺដើម្បីការពារនូវអ្វីដែលបានកើតមាននៅក្នុងរឿងក្ដីនេះរួចមកហើយ។ ហើយតុលាការត្រូវការទប់ស្កាត់អំពីការធ្វើពហិការណាមួយបញ្ហាដែលមេធាវីការពារក្ដី ខៀវ សំផន ដែលថាជាការគាបសង្កត់ ឬការគំរាមកំហែងដល់ពួកគាត់នេះ -- គឺថាការគំរាមកំហែងនិងការគាបសង្កត់ គឺថាពួកគាត់ត្រូវតែគោរពសេចក្ដីបង្គាប់របស់តុលាការ។ ខៀវ សំផន បានទទួលការជំនុំជម្រះប្រកបទៅដោយយុត្តិធម៌ដោយគោរពទៅតាមច្បាប់ គោរពទៅនឹងអ្វីដែលអង្គជំនុំជម្រះបានសម្រេច។ ដូច្នេះ ខ្ញុំមិនចំណាយពេលវេលាតតាំងក្នុងការបញ្ហានេះទេ ខ្ញុំបានស្ដាប់ទៅ គឺថាអំមិញបានជជែកគ្នាអស់រយៈពេលកន្លះម៉ោងរួចមកហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញា។

សូមអញ្ជើញ មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងសាធារណជន ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានវត្តមាននៅក្នុងសាលសវនាការនេះ ឬក៏បានទស្សនានៅពីចម្ងាយចំពោះសវនាការនេះ។

យើងខ្ញុំគោរពណាស់នូវអ្វីដែលជាសិទ្ធិរបស់ជនជាប់ចោទនៅក្នុងការមានតំណាងមេធាវីនៅក្នុងការការពារក្ដីរបស់គាត់។ វាចាំបាច់ណាស់ដែលគាត់ត្រូវមានអ្នកដែលជាជំនាញខាងច្បាប់នៅក្នុងការការពារក្ដីដើម្បីឲ្យដំណើរការក្ដីហ្នឹងប្រព្រឹត្តទៅដោយរលូនផងដែរ ហើយក៏ដើម្បីឲ្យមានសិទ្ធិរបស់គាត់នៅក្នុងការឆ្លើយតប ឬក៏នៅក្នុងការការពារក្ដីរបស់គាត់នោះត្រូវបានគោរពផងដែរ។ ក៏ប៉ុន្តែសម្រាប់យើងខ្ញុំដែលជាដើមបណ្ដឹងរដ្ឋប្បវេណី វាចាំបាច់ណាស់ផងដែរ ដែលសិទ្ធិនេះត្រូវ -- មិនត្រូវឲ្យមានប៉ះពាល់ទៅដល់ដំណើរការ ឬក៏ពេលវេលានៅក្នុងការទទួលបាននូវយុត្តិធម៌មួយក្នុងរយៈពេលមួយដ៏

សមរម្យនោះទេ។ ដូច្នេះហើយ បញ្ហាណាមួយដែលនាំឲ្យមានការបន្ទាយសវនាការ វាបានធ្វើឲ្យប៉ះពាល់ទៅដល់ខាងដើមបណ្ដឹងរដ្ឋប្បវេណីយើងខ្ញុំផងដែរ។ យើងខ្ញុំបានជម្រាបអំពីបញ្ហានេះរួចមកហើយ ប្រសិនបើគ្មានអ្វីដែលជាមូលហេតុសមស្របនោះទេ ការបន្ថយណាមួយគឺធ្វើឲ្យមានការប៉ះពាល់ដោយមិនសមហេតុផលទៅដល់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងការទទួលបាននូវយុត្តិធម៌ ដោយសារដើម្បីបណ្ដឹងរដ្ឋប្បវេណីមានអ្នកដែលស្លាប់ជាបណ្ដើរៗ ឬក៏ថាមិនអាចទទួល -- ឃើញសាលក្រមជាបណ្ដើរៗហើយ។

[០៩:៣៦:២៤]

ពាក់ព័ន្ធទៅនឹងរឿងលទ្ធភាពនៅក្នុងការចូលសវនាការ ដើម្បីធានាឲ្យសវនាការនេះប្រព្រឹត្តទៅបានរលូន ខ្ញុំគិតថាវាក៏ចាំបាច់ដែរ ដែលមានមេធាវីនៅក្នុងការជួយការពារសិទ្ធិរបស់លោក ខៀវ សំផន នៅក្នុងករណីដែលមានបញ្ហាណាមួយពាក់ព័ន្ធទៅនឹងមេធាវីផ្ទាល់ដែល -- របស់លោក ខៀវ សំផន នោះដែលពួកគាត់មិនចូលរួមនៅក្នុងសវនាការ។ ដូច្នេះ លទ្ធភាពនៅក្នុងការមានមេធាវីសម្រាប់ប្រចាំការនេះ ខ្ញុំគិតថាវាចាំបាច់ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំគិតថាក៏មិនត្រូវឲ្យមានការប៉ះពាល់ទៅដល់យុត្តិសាស្ត្ររបស់មេធាវីរបស់លោក ខៀវ សំផន ផ្ទាល់នៅក្នុងការការពារក្ដីរបស់ពួកគាត់ដែរ។ ហើយកន្លែងនេះគឺ លោកស្រីចៅក្រមជាអ្នកពិចារណាតាមទិដ្ឋភាពជាក់ស្ដែងថា តើអ្វីដែលជាការ -- វត្តមានរបស់មេធាវីប្រចាំការនេះនឹងប៉ះពាល់ទៅដល់យុត្តិសាស្ត្រនៅក្នុងការការពារក្ដីរបស់លោក ខៀវ សំផន ដែរឬទេ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំយល់ថា ពួកគាត់ត្រូវតែមានលទ្ធភាពនៅក្នុងការពិនិត្យមើលឯកសារ នៅក្នុងការតាមដានឲ្យបានពេញលេញនូវសំណុំរឿងរបស់លោក ខៀវ សំផន ក៏ដូចជាដំណើរការនៃសាលាក្ដី ដើម្បីឲ្យគាត់មានលទ្ធភាពនៅក្នុងការជំនួសនៅក្នុងករណីណាមួយដែលចាំបាច់ ជំនួសមេធាវីរបស់លោក ខៀវ សំផន។ ហើយនេះជាចំណុចមួយដែលខាងមេធាវីការពារក្ដីលោក ខៀវ សំផន ក៏ធ្លាប់បាននិយាយដែរ “យកមេធាវីដែលមិនបានមើលឯកសារ មិនបានដឹងពីរឿងរ៉ាវសោះ យកមកមើលឯកសារ -- យកមកការពារក្ដីលោក ខៀវ សំផន”។ នេះជាការមួយដែលប៉ះពាល់ទៅដល់សិទ្ធិលោក ខៀវ សំផន។ ដូច្នេះហើយ ចាំបាច់ណាស់ដែលត្រូវឲ្យមេធាវីដែលជាមេធាវីប្រចាំការនេះ មានលទ្ធភាពនៅក្នុងការពិនិត្យមើលឯកសារ តាមដានឯកសារ ហើយនិងសវនាការនេះឲ្យបានម៉ត់ចត់ នៅក្នុងករណីដែលត្រូវជំនួសមេធាវីលោក ខៀវ សំផន គឺគាត់អាចមានលទ្ធភាពគ្រប់គ្រាន់នៅក្នុងការជំនួស។ ខ្ញុំគិតថានេះជាបញ្ហាមួយដ៏សមស្របដែលគាត់អាចចូលរួមហើយនិងមាន

លទ្ធភាពនៅក្នុងការតាមដានឲ្យបានគ្រប់គ្រាន់។

ពាក់ព័ន្ធនឹងបញ្ហាទីកន្លែង។ ខ្ញុំមានការភ្ញាក់ផ្អើលបន្តិច ដែលមេធាវីការពារក្តីជាពិសេសលោក អាកទួរ វែកគែន គាត់រហូតទៅដល់និយាយថា ចង់ឲ្យមេធាវីប្រចាំការហ្នឹងទៅអង្គុយជាមួយចៅក្រមតែម្តង ឬក៏អង្គុយជាមួយព្រះរាជអាជ្ញា។ ក៏ប៉ុន្តែអ្វីដែលខ្ញុំចាប់អារម្មណ៍ខ្លាំងបំផុត គឺថាទីកន្លែងដែលបានរៀបចំនេះ ពេលនេះមានមេធាវីបីក្រុម។ គាត់យល់ថាវាប៉ះពាល់ទៅដល់ការអង្គុយ ទីកន្លែងអង្គុយ។ ពីមុនយើងបាន -- មានៗរហូតទៅដល់ មេធាវីមានរហូតទៅដល់បួនក្រុម។ មានទាំងមេធាវីរបស់លោក អៀង សារី និងមេធាវីរបស់ក្រុមមេធាវីរបស់លោកស្រី អៀង ធីរិទ្ធ ផងដែរ។ ហើយកន្លែងត្រូវបានចាត់ចែងសម្រាប់បួនក្រុម ហើយមិនមានបញ្ហាធំដុំទៅនឹងពាក់ព័ន្ធទៅនឹងការជំទាស់ ពាក់ព័ន្ធទៅនឹងទីកន្លែង។ តែពេលនេះ គ្រាន់តែមានមេធាវីពីរក្រុម ថែមមួយក្រុមទៀត ខ្ញុំគិតថាវាមិនប៉ះពាល់ទៅដល់ទីកន្លែងធូន់ធ្ងរទេ។ ដូច្នេះ ខ្ញុំគិតថានេះមិនជាបញ្ហាធំទេបាទ។ ហើយសូមអរគុណលោកប្រធាន។

[០៩:៣៩:៤២]

**ប្រធានអង្គជំនុំ៖**

បាទអរគុណនូវរាល់មតិយោបល់របស់ភាគី។

បាទសូមអញ្ជើញ! សុំបន្ថែមខ្លីបានហើយណា៎ះ! ជៀសវាងកុំនិយាយច្រំដែល បើភាគីមួយបាននិយាយហើយ សូម -- អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យនិយាយបន្ថែមទៀតទេ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

សូមអរគុណលោកប្រធាន។

ពិតណាស់លោកប្រធាន ខ្ញុំនិយាយខ្លីទេ។ ខ្ញុំគ្រាន់តែចង់ឆ្លើយតបទៅនឹងការលើកឡើងរបស់លោក កូប៉េ នៅពេលដែលគាត់បានស្នើទៅអង្គជំនុំជម្រះថា មេធាវីការប្រចាំការឲ្យមកអង្គុយខាងព្រះរាជអាជ្ញា ឬក៏ខាងដើមបណ្តឹងរដ្ឋប្បវេណីនោះ។ ខ្ញុំយល់ពីសាររបស់គាត់នេះហើយ គឺថាមានន័យថាមានការប្រទើសប្រទាំងគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រម ហើយនិងព្រះរាជអាជ្ញា។ ដូច្នេះ យើងទាំងអស់នេះ គឺថាយើងធ្វើដោយមានការផលប្រយោជន៍រួមគ្នា ដូច្នេះហើយ ខ្ញុំចង់បញ្ជាក់ឲ្យសម្រាប់សាធារណជន និងជនជាប់ចោទ គឺថាមិនមែនដូចគាត់លើកឡើងទេ គឺថាពួកយើងឯករាជ្យពីគ្នា។ អ៊ីចឹងមិនមែនជាសម្ព័ន្ធមិត្ត ឬក៏រួមដៃគ្នាអីទេ។ ដូច្នេះ ការសម្រេចរបស់អង្គជំនុំជម្រះនេះ គឺថាមិនមែនជាការអ្វីដែលយើងចង់បាន យើងទាមទារ យើងប្រាថ្នាចង់បានថាអ៊ីចឹងទេ។ គឺថាយើង ក៏ដូចជាមេធាវី

ការពារក្ដីដែរ គឺថាយើងទទួលនូវការសម្រេចរបស់អង្គជំនុំជម្រះ ដោយយើងមិនបានស្នើសុំទេ។ ដូច្នេះ ខ្ញុំចង់រំឭកពីចំណុចនេះឡើងវិញ ដើម្បីឲ្យយើងទាំងអស់គ្នា ក៏ដូចជាសាធារណជនខាងក្រោយ យល់ពីជំហររបស់ភាគីនីមួយៗ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវរាល់មតិយោបល់ដែលលើកឡើងរបស់ភាគី ពាក់ព័ន្ធនឹងសំណើសុំរបស់មេធាវីការពារក្ដីទាំងពីរក្រុម ហើយបញ្ហានេះអង្គជំនុំជម្រះនឹងយកទៅពិចារណាសម្រេចនាពេលក្រោយឆាប់ៗនេះ។

បាទ ជាបន្តទៀត អង្គជំនុំជម្រះសូមជ្រាបដល់ភាគី និងសាធារណជន ឲ្យបានជ្រាបថា អង្គជំនុំជម្រះចាប់ផ្ដើមសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង០០២/០២ អំពីអង្គហេតុពាក់ព័ន្ធទៅនឹង -- ត្រូវធ្វើសវនាការនូវវគ្គដំបូងនេះ គឺសហករណ៍ត្រាំកក់ រួមទាំងការប្រព្រឹត្តទៅលើពុទ្ធសាសនិកជន និងមន្ទីរសន្តិសុខក្រាំងតាចាន់។

សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដំបូងៗដែលនឹងត្រូវផ្ដល់សក្ខីកម្មលើប្រធានបទនេះ គឺសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCW-936, 2-TCCP-296, 2-TCCP-238, 2-TCW-954 និង 2-TCW-834។

[០៩:៤២:៤៣]

អង្គជំនុំជម្រះបានបញ្ជូនបញ្ជីឈ្មោះទាំងស្រុងទៅជូនទៅភាគី កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ រួចរាល់អស់ហើយ។ ឯកសារ E228.1។ សាក្សីទី១ ដែលនឹងត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ គឺសាក្សី 2-TCW-936។ មុននឹងចាប់ផ្ដើមស្ដាប់សក្ខីកម្មសាក្សី 2-TCW-936 អង្គជំនុំជម្រះសូមបញ្ជាក់អំពីបញ្ហានីតិវិធីមួយចំនួនជាមុនសិន។

អង្គជំនុំជម្រះសូមរំឭកដល់ជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ថា អនុលោមតាមវិធាន២១ អនុវិធាន១ ចំណុច(ឃ) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ អនុលោមតាមវិធាន៩០ នៃវិធានផ្ទៃក្នុង ប្រសិនបើជនជាន់ចោទសម្រេចមិនអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញា ភាគីទាំងអស់ និងមេធាវី មានសិទ្ធិសួរចំពោះជនជាប់ចោទ។

កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ តាមរយៈអ៊ីម៉ែលផ្ញើជូនមកមន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំ

ជម្រះសាលាដំបូង លោក នួន ជា និងលោក ខៀវ សំផន បានបង្ហាញជំហរថា ពួកគាត់នឹងមិនឆ្លើយតបទៅនឹងសំណួរទេ។ នៅក្នុងសវនាការបើកកិច្ចដំណើរការនីតិវិធីសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង០០២/០២ ដែលបានប្រព្រឹត្តកាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ជនជាប់ចោទ នួន ជា បានឆ្លើយថា ខ្លួនរក្សាជំហរក្នុងការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល។ ចំណែកឯជនជាប់ចោទ ខៀវ សំផន មិនបានឆ្លើយបញ្ជាក់ឲ្យបានច្បាស់លាស់អំពីជំហររបស់ខ្លួន ក្នុងការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះទេ។

នាពេលនេះ អង្គជំនុំជម្រះសួរទៅជនជាប់ចោទ ខៀវ សំផន ថាតើលោកនៅតែប្រកាន់ជំហររក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល ឬក៏មានការផ្លាស់ប្ដូរគោលជំហរនេះ ទៅជាការរក្សាសិទ្ធិក្នុងការឆ្លើយតបទៅនឹងសំណួររបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង និងសំណួររបស់ភាគីពាក់ព័ន្ធ ឬក៏យ៉ាងណា?

សូមអញ្ជើញលោក ខៀវ សំផន!

[០៩:៤៥:១៦]

**លោក ខៀវ សំផន៖**

បាទ អរគុណលោកប្រធាន។

ដោយមានការគាបសង្កត់ទៅលើមេធាវីរបស់ខ្ញុំដូចបងប្អូនរួមជាតិទាំងអស់គ្នាបានឃើញនឹងភ្នែកស្រាប់។ ខ្ញុំគ្មានអីសង្ឃឹមអំពីតុលាការ អំពីអង្គជំនុំជម្រះសាលាដំបូងមួយដែលមិនលម្អៀងទៀតទេ។ ដូច្នេះ ជារួម ខ្ញុំសូមរក្សាសិទ្ធិនៅស្ងៀមស្ងាត់។ ក៏ប៉ុន្តែ យោងទៅតាមបរិបទដែលមាននៅក្នុងសំណុំរឿង ០០២/០២ ខ្ញុំសូមអនុញ្ញាតធ្វើសេចក្ដីថ្លែងការណ៍នៅពេលណាមួយដែលសមស្រប។ សូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ខៀវ សំផន។

នៅពេលនេះ ក្រោយពីបានបញ្ជាក់ជនជាប់ចោទទាំងពីរអំពីជំហររក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ជនជាប់ចោទទាំងពីររូបនៅតែរក្សាជំហររបស់ខ្លួនបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែនិងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងពីជនជាប់ចោទ ឬពីសហមេធាវីការពារក្ដីឲ្យជនជាប់ចោទ។ ហេតុដូច្នេះ ជនជាប់ចោទ និង/ឬ មេធាវីការពារក្ដីឲ្យជនជាប់ចោទ ត្រូវមានការទទួលខុសត្រូវក្នុងការ

ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងឲ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបទៅនឹងសំណួរនៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីដែលសួរដោយអង្គជំនុំជម្រះ ឬភាគីពាក់ព័ន្ធ។

[០៩:៤៧:១៥]

ឥឡូវនេះ អង្គជំនុំជម្រះសូមលើកយកសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលបានជូនដំណឹងនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដាក់ឯកសារថ្មីមួយចូលក្នុងសំណុំរឿង និងទទួលយកឯកសារជាភស្តុតាង។ ឯកសារនេះមានផែនទីមួយដែលមានព្រំប្រទល់រវាងឃុំត្រពាំងធំខាងត្បូង និងឃុំអង្គតាសោមក្នុងស្រុកត្រាំកក់ត្រូវបានគូសជាស្រមោល។ លើសពីនេះទៀត សហមេធាវីនាំមុខអះអាងថាផែនទីរួមមានឈ្មោះទីកន្លែង និងចំណាងនីមួយៗដែលបង្ហាញពីទីតាំងសំខាន់ៗចំនួន ១៧កន្លែង ដែលដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-296 បញ្ជាក់ថា គាត់ធ្លាប់បានស្នាក់នៅ ឬធ្វើការនៅរបបកម្ពុជាប្រជាធិបតេយ្យ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ផែនទីនេះត្រូវបានរៀបចំឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីផ្អែកលើកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-296 នៅក្នុងសំណុំរឿង០០២ ហើយផែនទីនេះនឹងផ្ទៀងផ្ទាត់ដោយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអំឡុងពេលសួរដេញដោលលើរូបគាត់។ អង្គជំនុំជម្រះកត់សម្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-296 ទំនងជាផ្តល់សក្ខីកម្មនៅថ្ងៃស្អែកនេះ។ កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៥ មេធាវីការពារក្តី ខៀវ សំផន បានដាក់ចម្លើយតបជំទាស់ទៅនឹងសំណើនេះរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

ជាដំបូងនេះ អង្គជំនុំជម្រះសូមឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់បំភ្លឺថាតើនរណាជាអ្នករៀបចំផែនទីនេះឡើង? សំណើសុំត្រង់ កថាខណ្ឌ៨ លើកឡើងថាផែនទីនេះត្រូវបានរៀបចំឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី។ តើដើមបណ្តឹងរដ្ឋប្បវេណីឬមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកធ្វើ? កថាខណ្ឌ៦ នៅក្នុងសំណើសុំក៏បានលើកឡើងផងដែរ នៅក្នុងផែនទីមួយនេះបង្ហាញទីកន្លែងចំនួន១៧ ឈ្មោះទីកន្លែង និងចំណាងជើងនីមួយៗដែលដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់ស្នាក់នៅ ឬធ្វើការ។ ទោះបីជាយ៉ាងនេះក្តីមានតែឈ្មោះទីកន្លែងចំនួន១៦តែប៉ុណ្ណោះដែលត្រូវបានរៀបរាប់។ ម្យ៉ាងទៀត ឈ្មោះទីកន្លែងនីមួយៗពុំត្រូវបានបញ្ជាក់ច្បាស់

នៅលើផែនទីឡើយ។ តើសហមេធាវីនាំមុខអាចបំភ្លឺបានដែរឬទេ ថាតើសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងបង្ហាញទីតាំងទាំងនោះនៅលើផែនទីនេះយ៉ាងដូចម្តេច?

សូមអញ្ជើញលោកសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:៥០:២០]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមសាជាថ្មី។ ដោយសារមានវត្តមានរបស់តំណាងដើមបណ្តឹងរដ្ឋប្បវេណីផ្ទាល់ ដែលទទួលសិទ្ធិនៅក្នុងការសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណីនោះ ខ្ញុំសូមលោកប្រធានអនុញ្ញាតឱ្យលោកមេធាវី គី យ៉ីង *(តាមសូរស័ព្ទ)* ដើម្បីធ្វើការពន្យល់និងឆ្លើយជូនទៅនឹងសំណួររបស់លោកប្រធាន។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទប្រធានអង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[០៩:៥១:០៤]

**លោក យីគាំង លូ៖**

ជម្រាបសួរលោកប្រធាន លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់ទាំងក្នុងបន្ទប់សវនាការទាំងក្រៅបន្ទប់សវនាការ។ ពាក់ព័ន្ធទៅនឹងផែនទីនេះ ថាតើវាមានរៀបចំដោយរបៀបណា។ ខ្ញុំមានបញ្ហាបីដើម្បីពន្យល់ជូនអង្គជំនុំជម្រះ និងភាគីទាំងអស់។ ទី១ នេះគឺជាផែនទីដែលមាននៅក្នុងសំណុំរឿងរួចមកហើយ មិនមែនជាផែនទីដែលបានបង្កើតឡើងដោយយើងខ្ញុំ គឺថាវាមាននៅក្នុងសំណុំរឿងរួចទៅហើយ។ ផ្នែកទីមួយៗនៅក្នុងហ្នឹង គឺថាវាជួយយើងឱ្យបង្កើតទៅដល់ផែនទី ឬក៏ផែនទីថ្មី នោះគឺទីតាំងនៃទីកន្លែងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយយោង *(គ្មានការបកប្រែ)*--

សូមទោសដូចបាត់បង់ការបកប្រែបន្តិចអម្បាញ់មិញ លោកប្រធាន។

លោកប្រធានអស់លោក លោកស្រី តើស្តាប់ខ្ញុំឮទេ?

**ប្រធានអង្គជំនុំ៖**

បាទ អំមិញអតមានការបកប្រែជាភាសាខ្មែរ។

សូមអញ្ជើញៗ!

**លោក យីគាំង លូ៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមចាប់ផ្ដើមឡើងវិញ។ ផែនទីនេះ គឺមានក្នុងសំណុំរឿងរួចទៅហើយ។ ហើយផែនទីថ្មីនេះ គឺយើងធ្វើឡើងដោយសម្អាងទៅលើផែនទីដែលមាននៅក្នុងសំណុំរឿងរួចមកហើយ ដោយយើងដាក់ឈ្មោះនៃទីកន្លែងនានាដែលដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ ហើយចំណុចនេះក៏មាននៅក្នុងសំណុំរឿងទៀត។ យើងមិនបានដាក់ភស្តុតាងថ្មីចូលមកក្នុងផែនទីនោះទេ ប៉ុន្តែដោយសារអង្គជំនុំជម្រះបានស្នើសុំថា ឲ្យមានភាពគ្រប់គ្រាន់នូវព័ត៌មានទាំងអស់នៅក្នុងសំណុំរឿង និងចំណុចដែលខ្ញុំយើងខ្ញុំពន្យល់។ ទី២ គឺទីតាំងនានា។ ខ្ញុំកត់សម្គាល់ឃើញថាមានឈ្មោះ១៧កន្លែងទាំងអស់ ប៉ុន្តែយើងបានបញ្ជាក់តែ១៦កន្លែងទេ។ យើង -- ខ្ញុំបញ្ជាក់ថាមានតែ១៦កន្លែងទេ ហើយទាំងអស់នេះគឺមាននៅក្នុងសំណុំរឿងទៀត ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់ចូលនៅក្នុងសំណុំរឿង។

ចំណុចចុងក្រោយ ទាក់ទឹងទៅនឹងទីតាំងនានា គឺថាតាមអ្នកជំនាញ គឺថាមិនអាចកំណត់ទីតាំងឲ្យមានសុពលភាពបានទេ។ ដូច្នេះយើងមិនអាចកំណត់ទីតាំងភូមិនៅក្នុងផែនទីនេះបានទេ ប៉ុន្តែយើងអាចយ៉ាងហោចណាស់ឃើញត្រឹមថ្នាក់ឃុំ ដោយសារកំណត់ចំនួន១៦កន្លែង ដែលភាគច្រើនគឺថាមិនអាចកំណត់រហូតទៅដល់ថ្នាក់ភូមិនោះទេ ត្រឹមតែថ្នាក់ឃុំ។ ដូច្នេះ យើងបង្ហាញផែនទីនេះដើម្បីពន្យល់ថាតើដើមបណ្ដឹងរដ្ឋប្បវេណីធ្លាប់រស់នៅកន្លែងណា បើទោះណាទីតាំងដល់ថ្នាក់ភូមិមិនបានកំណត់ក្នុងផែនទីនេះក៏ដោយ។ សូមអរគុណលោកប្រធាន។

[០៩:៥៤:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី! អ៎! លោកស្រីចៅក្រម ហ្វេនស៍។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ទាក់ទងទៅនឹងមូលដ្ឋាននៅក្នុងសំណុំរឿង ដែលថាវាមាននៅក្នុងសំណុំរឿងរួចទៅហើយ គឺថាលោកមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជាអ្នករៀបចំផែនទីថ្មីនេះ។ តើលោកអង្គុយរៀបចំផែនទីនេះ ពិភាក្សារួមគ្នាជាមួយកូនក្ដីរបស់លោក ឬក៏យ៉ាងណា?

**លោក យីគាំង លូ៖**

សូមអរគុណលោកស្រី ចៅក្រម។ ដំណើរការនៃការរៀបចំផែនទីនេះ គឺខ្ញុំអានឯកសារទាំងអស់ដែលតាមប្រព័ន្ធរបស់យើង ហើយដកស្រង់ចេញមក ហើយខ្ញុំបានផ្ដល់ផ្នែកនីមួយៗទៅអ្នកជំនាញដើម្បី

ឲ្យគាត់កំណត់ទីតាំងនានានៅក្នុងផែនទីនេះ។ ដូច្នេះខ្ញុំបញ្ជាក់អំពីឈ្មោះ និងទីកន្លែងនេះ រួមគ្នាជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី។ ជាទីតាំងទេ ជាទីកន្លែងទេ ប៉ុន្តែមិនមែនផែនទីនោះទេ។ នៅក្នុងពេលសវនាការដើម្បីផ្តល់ឱកាសឲ្យគាត់អាចនិយាយថា -- ដើម្បីឲ្យច្បាស់ថាតើ គាត់ធ្លាប់រស់នៅកន្លែងនោះ ដូចបានបញ្ជាក់ក្នុងផែនទីឬក៏អត់។ ខ្ញុំត្រៀមខ្លួនរួចជាស្រេចដើម្បីឆ្លើយជូនលោក លោកស្រី ប្រសិនជាណាមានសំណួរណាមួយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមសួរសំណួរដូចតទៅ ទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ថាតើដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មដូចដែលបានកំណត់នៅក្នុងផែនទីនេះ ដូចដែលការកំណត់ទីតាំងនៅក្នុងផែនទីនេះ។ តើលោកបានឃើញផែនទីជាក់ស្តែងឬក៏អត់ ឬក៏គ្រាន់តែកំណត់ទីតាំងជាមួយកូនក្តីទេ?

[០៩:៥៦:៥៨]

**លោក យីគាំង លូ៖**

លោក លោកស្រី ចៅក្រម! ខ្ញុំសួរទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ថាតើខ្ញុំឆ្លើយដោយផ្ទាល់ ឬក៏ខ្ញុំរង់ចាំការកំណត់ពីលោកប្រធានឲ្យអ្នកណានិយាយសិន?

ក្រោយពីការរៀបចំផែនទីនេះរួចហើយ ដើមបណ្តឹងរដ្ឋប្បវេណីមិនមានឱកាសអង្គុយជាមួយខ្ញុំដើម្បីចង្អុលកំណត់ទីតាំងនីមួយៗនោះទេ។ តាមដែលខ្ញុំយល់នោះគឺ គាត់មិនអាចកំណត់ឈ្មោះទីតាំងភូមិឲ្យបានច្បាស់លាស់នោះទេ។ ហេតុដូច្នេះឯងបានជាខ្ញុំមិនអង្គុយជាមួយដើមបណ្តឹងរដ្ឋប្បវេណី កំណត់ទីតាំងភូមិនៅក្នុងផែនទីនេះទេ។ សង្ឃឹមថាខ្ញុំបានឆ្លើយទៅនឹងសំណួរអម្បាញ់មិញនេះ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មានន័យថា លោកព្យាយាមពិគ្រោះជាមួយដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីមិនអាចកំណត់ទីតាំងភូមិបាន។ នេះអ៊ីចឹងមែនទេ?

[០៩:៥៨:០៧]

**លោក យីគាំង លួ៖**

បាទ ខ្ញុំសូមអធ្យាស្រ័យចំពោះការច្របូកច្របល់នេះ។ ខ្ញុំសម្រេចថា មិនធ្វើការជាមួយដើមបណ្តឹងរដ្ឋប្បវេណីពិគ្រោះយោបល់ទេ ដោយសារថាគាត់មុនពេលសវនាការ នៅពេលសវនាការ មុនសវនាការផ្អាកហ្នឹង គឺថាយើងរួតរះរៀបចំផែនទីនេះ។ ដូច្នេះ ខ្ញុំក៏សម្រេច -- ខ្ញុំយល់ឃើញថា វាជាដំណើរការមួយវែងឆ្ងាយ បើកាលណាយើងពិគ្រោះយោបល់ជាមួយរដ្ឋប្បវេណី។ អ៊ីចឹងឯង ខ្ញុំក៏មិនបាច់ពិគ្រោះយោបល់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវនេះពេលវេលាយើងកំណត់ថា ថ្ងៃនេះយើងធ្វើស្តាប់សក្ខីកម្មសាក្សីមួយរូបនេះទំនងជាពេលវេលាហ្នឹងដូចជាអស់ទៅហើយ ដោយសារយើងធ្វើនីតិវិធីផ្សេងៗដែលមិនបានគ្រោងទុកនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់យើង។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនទៅសហព្រះរាជអាជ្ញានិងមេធាវីការពារក្តី ឲ្យក្រុម -- អ៎! ឲ្យលោក នួន ជា ថាអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅដើម្បីធ្វើសេចក្តីសន្និដ្ឋានទៅលើបញ្ហានេះ នៅចុងសវនាការថ្ងៃនេះ ប្រសិនបើសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី នួន ជា មានបំណងធ្វើដូច្នេះ។ ហើយបន្ទាប់មកទៀត អង្គជំនុំជម្រះ នឹងចេញសេចក្តីសម្រេចដោយផ្ទាល់មាត់មួយលើបញ្ហានេះ ឲ្យបានមុនអង្គជំនុំជម្រះដំណើរការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

[០៩:៥៩:៣៨]

នាពេលនេះ អង្គជំនុំជម្រះសូមបញ្ជាក់ជូនដល់ភាគី និងសាធារណជនអំពីលំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ។ ដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនស្តីពីលំដាប់លំដោយនៃអង្គហេតុដែលត្រូវធ្វើសវនាការរួចហើយ អង្គជំនុំជម្រះសូមរំឭកថា គ្មានការបែងចែកច្បាស់លាស់នៅក្នុងចំណោមអង្គហេតុនានាឲ្យដាច់ស្រឡះពីគ្នាឡើយ។ អាស្រ័យហេតុនេះ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី ឬអ្នកជំនាញអាចផ្តល់សក្ខីកម្មអំពីអង្គហេតុមួយ ឬច្រើនដែលខ្លួនបានដឹង ដើម្បីជៀសវាងការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញឲ្យត្រឡប់មកវិញនៅដំណាក់កាលក្រោយៗទៀតក្នុងសវនាការដដែលៗនោះ។ ពួកគេនឹងសួរសំណួរទាក់ទងនឹងអង្គហេតុទាំងឡាយដែលពួកគេបានដឹង។ ជាវិធានការទូទៅ ការសួរសំណួរទៅលើអង្គហេតុដែលមិនពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង០០២/០២នោះ អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឡើយ។

អនុលោមតាមវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងអ.វ.ត.ក លើកលែងតែមានការសម្រេចផ្សេងដោយអង្គជំនុំជម្រះ តើ/ឬ តាមការព្រមព្រៀងគ្នារវាងភាគី ជាពិសេសនៅពេលចៅក្រមមានបំណងសួរសំណួរបន្តពីសំណួរមុនៗ ឬសួរបញ្ជាក់បំភ្លឺ ឬនៅពេលមានការព្រមព្រៀងពីសំណាក់ភាគីតាំងសំណួរតែប៉ុណ្ណោះ ក្រៅពីករណីនេះ ការតាំងសំណួរទៅសាក្សី អ្នកជំនាញត្រូវធ្វើតាមលំដាប់លំដោយដូចខាងក្រោមនេះ៖

ប្រធានអង្គជំនុំជម្រះ ឬចៅក្រមជំនុំជម្រះ ដែលចាត់តាំងដោយប្រធានអង្គជំនុំជម្រះត្រូវតែចាប់ផ្ដើមសួរសំណួរបឋមមួយចំនួន បន្ទាប់មកសហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្ដី នួន ជា និង ខៀវ សំផន។

[១០:០១:២៣]

ការសាកសួរដើមបណ្ដឹងរដ្ឋប្បវេណីត្រូវដឹកនាំដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រោយពីការសួរសំណួររបស់ប្រធានអង្គជំនុំជម្រះ ឬចៅក្រមជំនុំជម្រះ ដែលចាត់តាំងដោយប្រធានអង្គជំនុំជម្រះ ហើយបន្ទាប់មកដើមបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវសាកសួរដោយសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្ដី នួន ជា និង ខៀវ សំផន។

នៅចុងបញ្ចប់នៃការសួរសំណួរដើមបណ្ដឹងរដ្ឋប្បវេណីអាចលើកឡើងនូវ ឬបញ្ជាក់ពីព្យសនកម្មដែលពួកគេបានទទួលរងពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០២។ នៅចំណុចនេះ អង្គជំនុំជម្រះសូមរំឭកឲ្យភាគីបានជ្រាបផងដែរថា ភាគីអាចជំទាស់ទៅនឹងការបន្តស្ដាប់នូវសក្ខីកម្មរបស់សាក្សីណាមួយបានប្រសិនបើភាគីយល់ឃើញថា សក្ខីកម្មបែបនោះមិនសម្ដែងឲ្យឃើញការពិត អនុលោមតាមវិធាន៩១ អនុវិធាន៣ នៃវិធានផ្ទៃក្នុង។

អង្គជំនុំជម្រះសូមរំឭកដល់ភាគីទាំងអស់ថា នៅក្នុងអំឡុងពេលសាកសួរ ឬផ្ដល់សក្ខីកម្មផ្ទាល់មាត់ ភាគីត្រូវប្រកាន់ភ្ជាប់នូវបទដ្ឋានវិជ្ជាជីវៈដែលមានការទទួលស្គាល់ អង្គជំនុំជម្រះនឹងមិនអត់ឱនចំពោះភាសាអសុរោះ ឬភាសាប្រមាថមើលងាយទៅលើភាគី សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកជំនាញ ឬបុគ្គលផ្សេងទៀតនោះឡើយ។

ជាបន្តទៅនេះ អង្គជំនុំជម្រះបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-936 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(មន្ត្រីតុលាការនាំសាក្សីចូលក្នុងបន្ទប់សវនាការ)*

[១០:០៤:៤៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី! តើលោកឈ្មោះអ្វី?

**លោក មាស សុខា៖**

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

រង់ចាំភ្លើងក្រហមនៅក្បាលមីក្រូហ្វូនចាំលោកនិយាយ ទើបសំឡេងរបស់លោកហ្នឹងចូលក្នុងប្រព័ន្ធចែកចាយសំឡេងនៅក្នុងបន្ទប់សវនាការនេះ។

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំបាទឈ្មោះ មាស សុខា នៅក្នុងឃុំជាងទង ស្រុកត្រាំកក់ ភូមិស្រែគ្រូ។

**ស៖** លោកឆ្លើយតាមសំណួររបស់យើងនឹងងាយស្រួលជាងណា៎ះ! លោក សុខា តើលោកកើតនៅថ្ងៃខែឆ្នាំណា ចាំទេ?

**ឆ៖** ចាំ។

**ស៖** លោកចាំក្បាលមីក្រូហ្វូនហ្នឹងមាន -- ឲ្យភ្លើងសញ្ញាក្រហមសិន សឹមនិយាយ អាហ្នឹងបានអ្នកបកប្រែហ្នឹងគេបកប្រែ ហើយអ្នកផ្សេងទៀតហ្នឹង ភាគីផ្សេងទៀតហ្នឹងអាចស្ដាប់បានណា៎ះ!

**ឆ៖** ខ្ញុំបាទឈ្មោះ មាស សុខ នៅឃុំជាងទង ភូមិស្រែគ្រូ ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** លោកកើតនៅឆ្នាំណា?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលសម្របសម្រួល ធ្វើក្បាលមីក្រូម៉េចឲ្យគាត់អាចមើលឃើញភ្លើងក្រហម សឹមឲ្យគាត់និយាយ ឲ្យគាត់ឆ្លើយ។ ដាក់បញ្ចិតទៅ! ម្ដងទៀត។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកកើតនៅថ្ងៃខែឆ្នាំណា? ចាំទេ? លោកឆ្លើយតែថ្ងៃខែឆ្នាំកំណើតបានហើយ។ សំណួរផ្សេងទៀត យើងនឹងសួរបន្តបន្ទាប់ដើម្បីលោកយល់ ហើយនិងងាយឆ្លើយណា៎ះ!

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំបាទឈ្មោះ មាស សុខា នៅឃុំជាងទង ភូមិស្រែគ្រូ ស្រុកត្រាំកក់ ខេត្តតាកែវ។

សូមសួរខ្ញុំពីជុំវិញហេតុការណ៍ក្នុង--

[១០:០៧:១៩]

**ស៖** អត់ទាន់សួរទេ។ លោកកើតនៅឆ្នាំណា? សួរថាកើតនៅឆ្នាំណា ឆ្លើយតែឆ្នាំកំណើតបានហើយ។

**ឆ៖** ខ្ញុំកើតនៅឆ្នាំ១៩៦០។

**ស៖** អរគុណ។ ហើយទីកន្លែង ទីលំនៅដ្ឋានសព្វថ្ងៃ តើលោកនៅទីកន្លែងណា?

**ឆ៖** ភូមិស្រែ--

**ស៖** លោកស្តាប់បានទេ យើងបានប្រាប់លោកហើយថា ចាំក្បាលមីក្រូហ្វូនឲ្យបានភ្លើងក្រហម បានលោកអាចនិយាយ បានចូលប្រព័ន្ធនៃការចែកចាយសំឡេងនៅក្នុងសាលសវនាការនេះទាំងមូល។ អាចឲ្យធ្វើភាគីពាក់ព័ន្ធ និងសាធារណជនបានស្តាប់នូវសម្តីរបស់លោកនិយាយ។ បើពុំដូច្នោះទេ មិនប្រព័ន្ធរបស់លោក លោកនិយាយឆ្លើយតែខ្លួនឯង ស្តាប់តែខ្លួនឯងប៉ុណ្ណោះ។

**ឆ៖** ខ្ញុំបាទឈ្មោះ មាស សុខា កើតនៅឆ្នាំ១៩៦០។ បច្ចុប្បន្ននៅភូមិស្រែគ្រូ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** បាទ អរគុណ។ តើលោកប្រកបមុខរបររកស៊ីធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** រកស៊ីអេតចាយ ហើយធ្វើស្រែ។

**ស៖** ឪពុករបស់លោកឈ្មោះអី?

[១០:០៨:៥៧]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទៅសម្របសម្រួលជាមួយគាត់ និយាយឲ្យគាត់ស្តាប់បានមើល៍។ ខ្ញុំដូចពន្យល់ជាមួយគាត់ច្រើនហើយ គាត់ដូចជាមិនទទួលបានការណែនាំរបស់យើងផង គាត់ស្តាប់អត់យល់ផងឬយ៉ាងម៉េច។ អង្គុយជិតគាត់ ហើយចុច ចាំនៅសម្របសម្រួល សម្រេចនៅខាងក្បាលមីក្រូដើម្បីឲ្យគាត់ឆ្លើយណ៎ះ!

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ឪពុករបស់លោក គាត់ឈ្មោះអ្វី?

**លោក មាស សុខា៖**

**ឆ៖** ឪពុករបស់ខ្ញុំ គាត់បានស្លាប់ជំនាន់ប៉ុល ពត។ ឈ្មោះ មាស គុណ។

**ស៖** ចុះម្តាយរបស់លោកគាត់ឈ្មោះអ្វី?

**ឆ៖** ឈ្មោះ ហ៊ុន គឹមសេង ហៅ ញ៉ូ។

**ស៖** ចុះប្រពន្ធរបស់លោក គាត់ឈ្មោះអ្វី?

**ឆ៖** ឈ្មោះ កែវ ហឿន។

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** កូនបីនាក់។

**ស៖** លោក មាស សុខា តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញនេះ ថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានឪពុកម្តាយ បុព្វញាតិ កូនបច្ឆាញាតិបងប្អូនប្រុសស្រីប្រពន្ធត្រូវទទួលយកស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី០០២ ទេ។ តើពិតមែនដែរឬទេ?

**ឆ៖** ពិតមែនហើយ។

[១០:១១:០៧]

**ស៖** ហើយថាតើលោកបានស្បថរួចហើយ មុននឹងចូលមកផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ គឺស្បថនៅមុខអ្នកតាដំបងដែកនៅមុខ នៅខាងកើតសាលសវនាការនេះ។ ពិតមែនដែរឬទេ?

**ឆ៖** ពិតមែនហើយ។

**ប្រធានអង្គជំនុំ៖**

យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោកក្នុងនាមជាសាក្សី។ អំពីសិទ្ធិលោក មាស សុខា ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនឆ្លើយ មិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះនាំឲ្យលោកអាច និងទទួលរងការចោទប្រកាន់។

អំពីករណីយកិច្ច លោក មាស សុខា ក្នុងនាមលោកជាសាក្សីត្រូវផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរ

ការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះ។ លោកត្រូវតែឆ្លើយទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយមួយឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចដែលយើងបានប្រាប់លោករួចហើយពីខាងលើអម្បាញ់មិញនេះ។ ក្នុងនាមលោកជាសាក្សីត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរ ដែលភាគី ឬចៅក្រមអង្គជំនុំជម្រះសួរលោក។

[១០:១២:៥៨]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក មាស សុខា តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យស៊ើបអង្កេតដែរឬទេ? ហើយប្រសិនបើមាន តើធ្វើប៉ុន្មានដង ហើយការធ្វើនោះនៅទីកន្លែងណា? នៅពេលណាដែរ?

**លោក មាស សុខា៖**

**ឆ៖** សក្ខីកម្មសួរចម្លើយ សំណួរពីរឿងជុំវិញហេតុការណ៍ក្រាំងតាចាន់ សួរនៅផ្ទះខ្ញុំម្តង ហើយខ្ញុំនាំទៅដល់ក្រាំងតាចាន់ម្តង។

**ស៖** អរគុណ។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោក មាស សុខា មានបានពិនិត្យមើល ឬអាននូវកំណត់ហេតុដែលបាន ដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បានខ្លះ អត់ខ្លះ វាយូរទៅវាកាន់ភ្លេចខ្លះ ប៉ុន្តែនៅចងចាំបានភាគច្រើនដែរ។

**ស៖** ហើយតាមសមត្ថភាពដែលលោកដឹង និងចងចាំ តើលោកអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុដែលស្តាប់ចម្លើយ ដែលលោកបានអានដើម្បីរំឭកការចងចាំ ឬបានពិនិត្យពិតជាត្រឹមត្រូវស៊ីសង្វាក់ស្របគ្នាទៅនឹងចម្លើយដែលលោកបានធ្វើសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែលឬទេ?

[១០:១៤:៣៤]

**ឆ៖** ពិតជាត្រឹមត្រូវ ពិតមែន ជុំវិញហេតុការណ៍នៅក្រាំងតាចាន់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់ជំទាស់សម្រាប់ជាប្រតិចារឹកសវនាការ គឺសម្រាប់សាក្សីទាំងអស់តែម្តង គឺថាក្នុងក្របខ័ណ្ឌនៃការ នៅក្នុងបណ្តឹងសាទុក្ខរបស់យើងៗបានលើកអំពីបញ្ហាដែលថាឲ្យសាក្សីអានចម្លើយមុនៗរបស់គាត់។ ដូច្នេះយើងយល់ថាការធ្វើអ៊ីចឹងគឺថាវាអាចរប៉ះពាល់ទៅដល់ចម្លើយរបស់គាត់នៅក្នុងសវនាការពេលនេះ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់ឲ្យមានការកត់ត្រាទុកជាប្រតិ-ចារឹកថាខាងមេធាវីការពារក្តីជំទាស់ជាថ្មីម្តងទៀតនៅក្នុងសវនាការសំណុំរឿង០០២/០២ នេះចំពោះការប្រើប្រាស់វិធីសាស្ត្រក្នុងការឲ្យសាក្សីអាននូវចម្លើយរបស់គាត់មុនៗហើយយកមកសួរគាត់នៅពេលនេះអ៊ីចឹងដើម្បីឲ្យមានការ -- ជៀសវាងនូវការសួរដដែលៗ -- ដែលថា គឺថាសាក្សីនៅពេលដែលគាត់មុនមកនេះ គឺថាសុំឲ្យគាត់អានឲ្យហើយទៅ។

[១០:១៥:៥៧]

**ប្រធានអង្គជំនុំ៖**

មានភាគីដទៃទៀតណាលើកឡើងពីបញ្ហានេះទេ ព្រោះយើងបានអនុវត្តនៅក្នុងសំណុំរឿង០០២/០១ ពេញមួយដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២/០១ ហ្នឹងរួចហើយៗមិនមានការជំទាស់តវ៉ាអ្វីទេ ហើយទើបមកដល់ពេលនេះជានីតិវិធីដែលយើងអនុវត្ត យើងសង្ឃឹមថានីតិវិធីដែលមិនមានការជំទាស់តវ៉ាពីមុនដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ យើងយកមកអនុវត្តជាបន្តនៅក្នុងសំណុំរឿង០០២/០២ ពីព្រោះសំណុំរឿងនេះ សំណុំរឿងតែមួយទេ យើងបំបែកកិច្ចដំណើរការនីតិវិធី យើងមិនមែនបំបែកសំណុំរឿងទេ។ ពាក់ព័ន្ធនឹងបញ្ហាដែលលើកឡើងនេះ តើមានភាគីដទៃទៀតហ្នឹងមានចង់ដឹងមានមតិយោបល់អីដែរទេ លើនីតិវិធីដែលអង្គជំនុំជម្រះបាន មានយុទ្ធសាស្ត្រក្នុងការអនុវត្តវិធីនេះកន្លងរួចមកហើយ ដោយបានសម្រេច ហើយបានស្តាប់ភាគីផងដែរលើបញ្ហានេះ ដើម្បីសម្រួលដល់កិច្ចដំណើការឲ្យប្រព្រឹត្តទៅបានឆាប់រហ័ស។

សូមអញ្ជើញលោក កូប៉េ!

[១០:១៧:១៨]

**លោក វិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ បាទ យើងខ្ញុំបានដាក់សំណើនៅក្នុងសារណារបស់ខ្ញុំជាច្រើនដើម្បីធ្វើម៉េចឱ្យវាឈានទៅដល់ការស្វែងរកនូវការពិតដែលថានៅអ្វីដែលសាក្សីបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួនមុនៗ។ នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់យើងខ្ញុំ ប្រហែលជាអង្គជំនុំជម្រះអាចដឹងពីការអនុវត្តបែបនេះហើយ ជាការពិតហើយថាមានបញ្ហាដទៃៗទៀតដែលកំពុងតែមានបញ្ហាពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីជាបន្តបន្ទាប់។ ប្រសិនណាជាមិនជាយល់ទាស់អ្វីនោះទេ ខ្ញុំសូមជំទាស់តវ៉ាដូចខាងក្រោមនេះ ជាមួយនឹងសាក្សីរបស់អង្គជំនុំជម្រះៗ។

ដូច្នេះ ខ្ញុំសូមប្រគល់តួនាទីជូនទៅអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងការអនុវត្តក្នុងការសាកសួរ -- តើស្តាប់ខ្ញុំឮ? ការអនុវត្តក្នុងការចោទសួរទៅសាក្សី គឺមិនមែនគ្រាន់តែជា -- មិនមែនជាដើមបណ្តឹងគ្រាន់តែជាដើមបណ្តឹងរដ្ឋប្បវេណីទេ។ ទោះបីយើង ខ្ញុំមិនបានរៀបចំរួចទៅហើយក្តី គឺថាពាក់ព័ន្ធ ដោយសារដើមបណ្តឹងរដ្ឋប្បវេណី គឺមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសួរ ហើយគាត់មិនបានផ្តល់ធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែកទេ។

**ប្រធានអង្គជំនុំ៖**

សូមសម្រាកបន្តិចសិន ផ្អាកបន្តិចសិនលោក កូប៉េ មានបញ្ហាបច្ចេកទេស។

*(មានបញ្ហាបច្ចេកទេស)*

*(ចៅក្រមពិភាក្សាគ្នា)*

ឥឡូវនេះដោយសារបញ្ហាមានកំហុសបច្ចេកទេសនៅ -- ដូច្នេះមិនអាចដំណើរការបានទេ ហើយជិតដល់ពេលសម្រាកផងដែរ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកតែម្តងទៅ ហើយចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលរកកន្លែងសមរម្យសម្រាប់សាក្សីរូបនេះបានសម្រាកនៅក្នុងរយៈពេលឈប់សម្រាក ហើយនិងឱ្យអញ្ជើញគាត់ត្រឡប់មកវិញនៅបានមុនពេលតុលាការចូលមកបន្ទប់សវនាការ។ សម្រាកសិនចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២២នាទី ដល់ម៉ោង ១០:៤៨នាទី)*

[១០:៤៨:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

អម្បាញ់មិញនេះអង្គជំនុំជម្រះបានស្តាប់នូវសេចក្តីជំទាស់របស់មេធាវីការពារក្តីទាំងពីរក្រុមលើនីតិវិធីដែលអង្គជំនុំជម្រះបានអនុវត្តនូវការអនុញ្ញាតឲ្យសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី អាននូវកំណត់ហេតុ ដែលខ្លួនបានផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតដែលធ្វើជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំពីព្រោះរឿងហេតុហ្នឹង វាយូរហើយ ហើយកិច្ចការនេះ អង្គជំនុំជម្រះធ្លាប់បានអនុវត្តនៅក្នុងសំណុំរឿង ០០២/០១ រួចហើយ។ ហើយពេលនេះ គឺនៅមានមតិជំទាស់លើបញ្ហានេះ ដើម្បីពន្លឿននូវកិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្តីដាក់នូវសេចក្តីជំទាស់របស់ខ្លួនជាលាយលក្ខណ៍អក្សរ។ ហើយទន្ទឹមនឹងនេះ គឺសុំឲ្យបង្ហាញច្បាស់លាស់នូវកថាខណ្ឌដែលពាក់ព័ន្ធនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនដែលបានលើកឡើង មូលហេតុនៃការប្តឹងសាទុក្ខហ្នឹងទៅតុលាការកំពូល ចំពោះសំណុំរឿង០០២/០១ ដើម្បីឲ្យអង្គជំនុំជម្រះហ្នឹងមានមូលដ្ឋានពិចារណាសម្រេចនៅលើបញ្ហានេះ នៅក្នុងពេលសមស្របឆាប់ៗខាងមុខនេះ។

បាទជាបន្តទៅនេះ អង្គជំនុំជម្រះបន្តកិច្ចដំណើរការនីតិវិធី ដែលដើម្បីពន្លឿននៅក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ។

[១០:៥០:៣០]

ក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលទៅសាក្សី មាស សុខាហ្នឹង មុនភាគីដទៃទៀតនូវរឿងក្តី ពីព្រោះសាក្សីនេះ គឺស្នើសុំឡើងដោយសហព្រះរាជអាជ្ញា។ ហើយសូមបញ្ជាក់ថាសហព្រះរាជអាជ្ញា រួមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលកន្លះថ្ងៃ។ បានន័យថាមួយពេលនេះ ហើយនិងមួយពេលរសៀលទៀត ពីព្រោះយើងមានការយឺតយ៉ាវនៅក្នុងការចាត់ចែងក្នុងការសួរ -- ក្នុងការដំណើរការនីតិវិធីស្តាប់សក្ខីកម្មសាក្សីរូបនេះ។

សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក សេង លាង៖**

បាទសូមអរគុណលោកប្រធាន។ ជាបឋមខ្ញុំបាទសូមគោរពលោក លោកស្រីចៅក្រម ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសវនាការនាពេលនេះ។

ហើយជម្រាបសួរលោកសាក្សី។ ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ថ្ងៃនេះ ខ្ញុំបាទមានសំណួរមួយចំនួនចង់សួរទៅកាន់លោកសាក្សីឱ្យជួយបំភ្លឺដល់អង្គសវនាការទាំងមូលនៅលើអង្គហេតុ ដែលពាក់ព័ន្ធជាមួយនឹងលក្ខខណ្ឌការងារ និងការរស់នៅក្នុងស្រុកត្រាំកក់ នៅក្នុងអំឡុងពេលរបបគ្រប់គ្រងរបស់ខ្មែរក្រហម។ ហើយបន្ទាប់មកទៀត សហការីរបស់ខ្ញុំគឺលោក ខេល នឹងមានសំណួរមួយចំនួនទៅលើបញ្ហាមួយចំនួន ដែលពាក់ព័ន្ធទៅនឹងការឃាត់ខ្លួនក្រុមគ្រួសាររបស់លោកផ្ទាល់ និងបញ្ហាមួយចំនួនទៀតដែលពាក់ព័ន្ធជាមួយនឹងគុកក្រាំងតាចាន់។ ប្រធានបទដំបូងដែលខ្ញុំចង់សួរទៅកាន់លោកសាក្សីគឺពាក់ព័ន្ធជាមួយនឹងការដ្ឋានការងារ និងសហករណ៍នៅឃុំជាងទង ស្រុកត្រាំកក់ នៅចន្លោះខែមេសា ឆ្នាំ១៩៧៥ រហូតដល់ ខែមិថុនា ឆ្នាំ១៩៧៦។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង លាង៖**

**ស៖** សំណួរដំបូងរបស់ខ្ញុំហ្នឹង សុំសួរទៅកាន់លោកសាក្សីថា តើក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ លោករស់នៅឯណា?

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំបាទសូមគោរពអង្គចៅក្រម តុលាការជាទីគោរព។ ខ្ញុំរស់នៅឃុំជាងទង ភូមិស្រែគ្រូ ស្រុកត្រាំកក់ ខេត្តតាកែវ ក្រោយពីថ្ងៃ១៧ មេសា។

**ស៖** បាទ អរគុណលោកសាក្សី។ សំណួរបន្ទាប់របស់ខ្ញុំទៀតគឺ នៅក្នុងកិច្ចសម្ភាសន៍មួយរបស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត នៅក្នុងកិច្ចសម្ភាសន៍របស់លោក នៅក្នុងឯកសារ D25/31 ត្រង់ ERN ជាភាសាអង់គ្លេស 00223494, ERN ជាភាសាខ្មែរ 00163511 និង ERN ជាភាសាបារាំង 00178111 លោកបាននិយាយថា៖ “គេចាត់ឱ្យលោកទៅលើកអាចម៍គោ និងជីកប្រឡាយនៅក្នុងកងកុមារ”។ សំណួរចង់សួរបញ្ជាក់ថា តើនៅពេលដែលលោកកំពុងតែធ្វើការ នៅក្នុងកងកុមារនោះ តើគេអនុញ្ញាតឱ្យលោក រស់នៅជាមួយនឹងឪពុកម្តាយរបស់លោកដែរឬទេ?

**ផ៖** ខ្ញុំបាទរស់នៅតាមកងចល័ត ប៉ុន្តែខ្ញុំឃ្វាលគោរហូត ខ្ញុំមិនដែលរើសអាចម៍គោទេ ហើយរែកដី ក៏ខ្ញុំមិនដែលរែកដែរ គេឲ្យខ្ញុំឃ្វាលគោ តាំងពីផ្ទះទៅដល់គុកក្រាំងតាចាន់។

[១០:៥៥:០០]

**ស៖** អរគុណសាក្សីដែលបានឆ្លើយយ៉ាងក្បោះក្បាយ។ ប៉ុន្តែខ្ញុំសុំឲ្យលោកសាក្សីមេត្តាឆ្លើយឲ្យខ្លីៗនូវសំណួរដែលខ្ញុំសួរ។ សំណួរផ្សេងទៀត ខ្ញុំនឹងសួរបន្ថែមទៀត។ ដូច្នេះ លោកកុំឆ្លើយហួសអំពីអ្វីដែលខ្ញុំបានសួរដើម្បីឲ្យងាយស្រួលក្នុងការតាមដាន។ ចុះលោកអាចបញ្ជាក់ម្តងទៀតបានទេថាតើលោកគេអនុញ្ញាតឲ្យលោករស់នៅជាមួយនឹងឪពុកម្តាយរបស់លោកដែរឬទេ នៅពេលដែលលោកធ្វើការនៅក្នុងកងកុមារ?

**ផ៖** ពេលនេះគេអនុញ្ញាតឲ្យខ្ញុំនៅ ពីព្រោះខ្ញុំវាតូចជាងគេ។ គេឲ្យខ្ញុំនៅផ្ទះសម្រាប់មើលគោតាមកង។

**ស៖** សំណួរបន្ទាប់ទៀតរបស់ខ្ញុំសួរលោកថា តើនៅក្នុងកងរបស់លោកមានកុមារប៉ុន្មាននាក់?

**ផ៖** ខ្ញុំមានតែប្រាំមួយនាក់ទេ អ្នកឃ្វាលគោនោះ។

**ស៖** តើពួកគេមានអាយុប្រហែលជាប៉ុន្មានដែរ?

**ផ៖** អាយុប្រហាក់ប្រហែលគ្នា។ ប៉ុនគេស្លាប់បាត់អស់ហើយ។

**ស៖** នៅក្នុងឃុំរបស់លោកនៅក្នុងរបបខ្មែរក្រហមតើមានកុមារណាម្នាក់ត្រូវបានគេអនុញ្ញាតទៅសាលារៀនដែរឬទេ?

**ផ៖** ចំណែកកុមារជំនាន់ខ្មែរក្រហម ពុំមានអ្នកណាអនុញ្ញាតឲ្យចូលសាលារៀនទេ។ បើរៀនមានតែរៀនក្រោមម្លប់ឈើ ហើយនិងប៊ិកសរសេរនឹងស្លឹកប្រហោងពីងពង់ឫស្សីនិងបៃ។

[១០:៥៧:៣៦]

**ស៖** លោកបាននិយាយថា បើរៀន រៀននៅក្រោមដើមឈើ។ ចុះមានរឿងអ្វីកើតឡើងចំពោះសាលារៀន?

**ផ៖** សាលារៀនគេពុំដែលឃើញមានសាលារៀនផង ក្នុងទីអារាមគេដាក់តែគ្រាប់បែបនិងគ្រាប់ផ្លោងសម្រាប់ឃ្លាំងអាវុធ។

**ស៖** តាមដែលលោកដឹង ថាតើកុមារដែលគេចាត់ឲ្យទៅធ្វើការនៅក្នុងកងកុមារហ្នឹងចាប់ពីអាយុប៉ុន្មានទៅត្រូវតែទៅធ្វើការនៅក្នុងកងកុមារ?

**ឆ៖** ពី១០ឆ្នាំទៅ១៤ឆ្នាំ គេឲ្យទៅតាមកង។ ពី១៥ឆ្នាំគេឲ្យទៅកងយុវជនត្រៀម។

**ស៖** តើវាខុសគ្នាយ៉ាងដូចម្ដេចរវាងកងកុមារ និង កងត្រៀម? លោកអាចបញ្ជាក់បានទេ?

**ឆ៖** កងត្រៀមនិងកងកុមារវាខុសគ្នាត្រង់ថា ក្មេងសម្រាប់ឲ្យយុវជនធំៗគេប្រើរែកដីប្រឡាយ និងជីកត្រពាំងធំៗ។

**ស៖** ឥឡូវបែរមកនិយាយអំពីការងារជីកប្រឡាយម្ដង។ សូមលោកនិយាយលម្អិតបន្តិចទៅមើល៍ តើគេឲ្យលោកធ្វើអ្វីនៅពេលដែលកងរបស់លោកត្រូវបានគេចាត់ឲ្យទៅជីកប្រឡាយ?

**ឆ៖** ចំណែករូបខ្ញុំពុំដែលបានរែកត្រពាំង ឬជីកប្រឡាយទេ ព្រោះខ្ញុំគេចាត់ឲ្យតែមើលគោតែមួយមុខ ព្រោះអ្នករែកគេផ្សេង ព្រោះខ្ញុំវាតូចជាងគេ គេពុំដែលប្រើខ្ញុំទេ។

[១១:00:00]

**ស៖** តើលោកអាចបញ្ជាក់បានទេថា ម៉ោងធ្វើការរបស់លោក លោកចាប់ផ្ដើមធ្វើការពីម៉ោងប៉ុន្មានទៅ?

**ឆ៖** ម៉ោងខ្ញុំមើលគោកំណត់តែភ្លឺ មើលគោ ដឹកគោទៅចង និងដេញគោទៅឃ្វាល ហើយទល់យប់យើងនាំគ្នាចូល ដេញគោចូលក្រោលវិញ ហើយពេលយប់ហូបបាយ ពេលថ្ងៃត្រង់គេយកបាយទៅឲ្យ។

**ស៖** តើមានពេលខ្លះគេដែលតម្រូវឲ្យលោកធ្វើការនៅពេលយប់ដែរឬទេ?

**ឆ៖** ចំណែកពួក -- ចំណែកខ្ញុំក្មេង គេមិនដែលឲ្យធ្វើយប់ទេ។ មានតែអ្នកធំៗ យុវជនពេញវ័យ។

**ស៖** ឥឡូវបែរមកនិយាយអំពីការងារនៅក្នុងកងកុមាររបស់លោកវិញ។ តើលោក -- នៅពេលដែលលោកកំពុងធ្វើការក្នុងកងកុមារនោះ តើលោកមានសេរីភាពពេញលេញក្នុងការដើរហើរដែរឬទេ?

**ឆ៖** សេរីភាពដើរហើរ ពុំមានសេរីភាពទេ។ អត់មានពេលដើរហើរលេងបានទេ ព្រោះគេដាក់កំណត់ឲ្យយើងឃ្វាលគោ តែបាត់គោមួយ ឬងាប់គោមួយគេដាក់ទោស យកទៅសម្លាប់ចោល។

[១១:0២:0៩]

**ស៖** តើលោកដែលមានជួបប្រទះក្នុងករណីដែលកុមារដែលគេចាត់ឲ្យមើលគោ ហើយបាត់គោ ហើយត្រូវគេដាក់ទោសដែរឬទេ?

**ឆ៖** ខ្ញុំពុំបានដែលជួបប្រទះទេតាំងពីខ្ញុំចេញពីផ្ទះឆ្នាំ៧៦មក ខ្ញុំទៅជាប់គុកនៅក្រាំងតាចាន់រហូត។

**ស៖** សួរថា តើគេអនុញ្ញាតឲ្យលោកទៅលេងឪពុកម្ដាយរបស់លោកញឹកញាប់ដែរឬទេ?

**ឆ៖** អនុញ្ញាតឲ្យមកផ្ទះ ពុំមានដែលអនុញ្ញាតឲ្យមកផ្ទះទេ ព្រោះតែ -- មានតែលួចរត់មក។ តែលួចរត់មកគេតាមឃើញ គេវ៉ៃគេដំយកទៅកងវិញ។

**ស៖** លោកនិយាយថានៅពេលដែលលោកលួចទៅលេងផ្ទះ ហើយគេដាក់ទណ្ឌកម្មលោកដោយ -- ក្រៅពីទណ្ឌកម្មវាយដំ តើមានទណ្ឌកម្មអីផ្សេងទៀតដែរឬទេ?

**ឆ៖** --

[១១:០៤:១៣]

**លោក វ៉ិចទ័រ កូប៉េះ**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក កូប៉េ!

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំសូមឲ្យលោកប្រធានបង្គាប់ទៅតំណាងសហព្រះរាជអាជ្ញាមេត្តាកុំសួរសំណួរនាំមុខ។ សុំឲ្យសួរសំណួរបើកតែម្ដង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក កូប៉េ ហើយនេះជាគោលការណ៍ដែលត្រូវអនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការហើយ សំណួរបើក អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមានតាំងសំណួរនាំមុខឡើយ។

[១១:០៥:១០]

**សួរដោយលោក សេង លាង៖**

សុំមិនឆ្លើយតបទេ ប៉ុន្តែខ្ញុំសុំបន្តទៅសំណួរបន្តទៅមុខទៀត។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត លោកនិយាយអំពីការហូបបាយរួមគ្នានៅក្នុងសហករណ៍។ តើលោកអាចបញ្ជាក់បានទេ ថានៅក្នុងស្រុកត្រាំកក់ តើគេបង្កើតសហករណ៍ ហើយតម្រូវឲ្យហូបបាយរួមគ្នា ឬសមូហភាពនៅឆ្នាំណា?

**លោក មាស សុខា៖**

**ឆ៖** ហូបបាយរួមគ្នា គេហូបជាក្រុមពីឆ្នាំ៧៤ បានរយៈមួយខែ ហើយរំសាយពីបាយរួមហ្នឹង

ទៅ គេរំសាយឲ្យហូបជាឯកជនបានរយៈដល់ឆ្នាំ៧៥ បែក៧៥ រហូតមកទល់៧៦ បានគេរួមសហ-
ករណ៍វិញ។

**ស៖** នៅពេលដែលគេឲ្យហូបបាយនៅសហករណ៍ តើលោកហូបបាយនៅឯណា?

**ឆ៖** ហូបបាយនៅភូមិស្រែគ្រូ ឃុំជាងទង ស្រុកត្រាំកក់ នៅដដែល។

**ស៖** តើមានមនុស្សប៉ុន្មាននាក់ហូបបាយជាមួយលោកនៅទីនោះ?

**ឆ៖** ក្រុមខ្ញុំមានតែប្រាំមួយនាក់ និងចំណែកពួកក្រុមឃ្វាលគោ។ ចំណែកគេដទៃទៀតមាន
គ្នាច្រើនរាប់រយនាក់ ខ្ញុំមិនបានចាំមនុស្សទាំងអស់នោះទេ។

**ស៖** តើគេឲ្យលោកហូបអ្វីនៅពេលបាយ?

**ឆ៖** ពេលបាយគេឲ្យហូបបាយមួយវែកហ្នឹង ហើយសម្លដើមចេក ឬសម្លព្រលិត សម្លត្រកួន
ស្លជាមួយមាន់ចូលក្នុងបង្គន់អាចម៍ ឬចូលក្នុងស្អរអីហ្នឹងគេយកស្លឲ្យហូបទៅ។

**ស៖** តើលោកហូបឆ្អែតដែរឬទេ នៅពេលនោះ?

**ឆ៖** អត់ឆ្អែតទេ ព្រោះបាយតិច។

**ស៖** នៅពេលដែលហូបមិនឆ្អែត តើមានប្រជាជនណាម្នាក់ដែលរាយការណ៍ប្រាប់ប្រធាន
សហករណ៍ទេ អំពីបញ្ហាហូបមិនឆ្អែត?

**ឆ៖** ពុំដែលមានប្រជាជនណារាយការណ៍ឲ្យប្រធានសហករណ៍ទេ ព្រោះខ្លាចប្រធានសហ-
ករណ៍យកទៅសម្លាប់ចោល។

[១១:០៨:៤២]

**ស៖** នៅក្នុងកិច្ចសម្ភាសន៍មួយរបស់ម្ដាយលោក ដែលបានសម្ភាសជាមួយនឹងការិយាល័យសហ
ចៅក្រមស៊ើបសួរនៅក្នុងបទសម្ភាសន៍ឯកសារលេខ D25/30 ត្រង់ ERN ជាភាសាអង់គ្លេស 002234
87, ERN ជាភាសាខ្មែរ 00163504 និង ERN ជាភាសាបារាំង 00178423។ ម្ដាយរបស់លោកបាន
និយាយថា៖ “ដោយសារធ្វើបាយរួម ហូបមិនឆ្អែត ហើយនិយាយថាគ្មានកម្លាំងធ្វើការ និងពេលដែល
ម្ដាយរបស់លោកនិយាយពីបញ្ហាហូបមិនឆ្អែក ពួកគេបានកត់ត្រាទុក”។ សំណួរចង់សួរថា តើលោកដឹង
ថាម្ដាយលោករាយការណ៍ទៅកាន់នរណាអំពីបញ្ហាហូបមិនឆ្អែត?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំសូមជំទាស់សំណួរនេះ ពីព្រោះសាក្សីអាចឆ្លើយបញ្ជាក់អំពីព្រឹត្តិការណ៍ដែលកើតឡើងចំពោះខ្លួនឯង ប៉ុន្តែលោកមិនអាចឆ្លើយនូវអ្វីដែលអ្នកដទៃបានដឹងបានឮនោះទេ។ សូមជំទាស់ជាមួយនឹងសំណួរនេះ។ ការឆ្លើយរបស់សាក្សីនឹងនាំឲ្យមានតែការសន្និដ្ឋានតែប៉ុណ្ណោះ បាទ សូមអរគុណ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមបន្ថែមបន្តិច ការជំទាស់មួយទៀត។ សហភាតារបស់ខ្ញុំបានបញ្ជាក់អម្បាញ់មិញនេះគឺថា មិនដឹងថាគាត់យោងទៅលើឯកសារណា ខ្ញុំឮថា D25/30 ប៉ុន្តែតាមស្តាប់តាមការបកប្រែនោះគឺថា យើងមិនដឹងថាជាឯកសារចេញមកពីសាក្សី ឬក៏ពីខាងណា។ អ៊ីចឹង សូមលោកសហព្រះរាជអាជ្ញាជួយបញ្ជាក់ ថាតើឯកសារពិតប្រាកដនោះ ឯកសារមួយណា?

[១១:១១:១៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ វាក៏មានសារប្រយោជន៍ដល់មេធាវីការពារក្តីផងដែរក្នុងការរៀបចំសំណួរទាក់ទងសួរសំណួរនៅសហករណ៍ ឬក៏សួរទៅម្តាយរបស់គាត់ថាតើ -- យើងដឹងថារឿងនេះកើតក្នុងខែមិថុនា ឆ្នាំ៧៦។ ប៉ុន្តែការតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញានេះគឺហាក់បីដូចជាមិនមានសារប្រយោជន៍អ្វីទេ។

**លោក សេង លាង៖**

លោកប្រធាន ខ្ញុំគិតថា សំណួរដែលខ្ញុំបានមុននឹងបានចាប់ផ្តើមសួរនេះ ខ្ញុំបានជម្រាបអំពីប្រធានបទដែលខ្ញុំត្រូវសួរ គឺសួរពាក់ព័ន្ធទៅនឹងលក្ខខណ្ឌរស់នៅ និង -- ខ្ញុំបានបញ្ជាក់ថា ខ្ញុំនឹងសួរពាក់ព័ន្ធទៅនឹងការដ្ឋានការងារ និងសហករណ៍នៅឃុំជាងទង ស្រុកត្រាំកក់ នៅចន្លោះខែមេសា ឆ្នាំ១៩៧៥ ដល់ខែមិថុនា ឆ្នាំ១៩៧៦។ ដែលបញ្ហាពាក់ព័ន្ធជាមួយនឹងការដ្ឋានការងារ និងសហករណ៍នេះ គឺមានចែងនៅក្នុងដីកាដំណោះស្រាយ។

ដូច្នេះ តើខ្ញុំអាចបន្តសំណួរតទៅទៀតបានទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

ដោះស្រាយសំណួរនេះមិនទាន់បានដោះស្រាយផង បន្តទៅណាទៀត គឺគេអំមិញជំទាស់ គឺទី១ គេឲ្យបង្ហាញបញ្ជាក់ឡើងវិញឡើងឯកសារហ្នឹង វាមកពីប្រភពណា ហើយបានសួរអ្នកណា? នេះគឺភាពមិនច្បាស់លាស់។ ទី២ តើលោកមានមតិយោបល់អ្វីដែលគេជំទាស់នូវការតាំងសំណួររបស់លោកអម្បាញ់មិញនេះនូវមូលហេតុនៃការជំទាស់ក្នុងការតាំងសំណួរ តើលោកការពារនូវគោលជំហរនូវការតាំងសំណួរនេះបែបណា ដើម្បីឲ្យអង្គជំនុំជម្រះហ្នឹងពិចារណាសម្រេចទៅលើមតិជំទាស់របស់ភាគីក្នុងការតាំងសំណួរអម្បាញ់មិញនេះ។

**លោក សេង លាង៖**

ចំពោះសំណួរដែលឲ្យខ្ញុំបញ្ជាក់អំពីលេខឯកសារ គឺឯកសារនៅកិច្ចសម្ភាសន៍របស់ម្តាយរបស់សាក្សីជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារលេខ D25/30 នេះគឺជាឯកសារ។ ចំពោះសំណួរដែលបានលើកឡើងថា គាត់មានការធុញទ្រាន់ ឬក៏យ៉ាងណាទៅនឹងការសួរសំណួររបស់ខ្ញុំនេះ ខ្ញុំគិតថាសំណួរនេះគឺវាពាក់ព័ន្ធទៅនឹងប្រធានបទដែលខ្ញុំបានជម្រាបពីខាងដើមហើយ។

**ប្រធានអង្គជំនុំ៖**

លោកឆ្លើយតបនឹងសេចក្តីជំទាស់គេទាំងការតាំងសំណួរហ្នឹងដែរឬទេ? ហើយឆ្លើយយ៉ាងម៉េចទៅ ដើម្បីឲ្យអង្គជំនុំជម្រះសម្រេច?

**លោក សេង លាង៖**

លោកប្រធាន ខ្ញុំដូចជាបានឆ្លើយតបទៅនឹងសំណួរមួយហើយ ដែលពាក់ព័ន្ធជាមួយនឹងការបង្ហាញលេខឯកសារ ហើយចំពោះសំណួរមួយទៀតដែលពាក់ព័ន្ធជាមួយនឹងការលើកឡើងរបស់លោកកូប៉េ ខ្ញុំក៏ដូចជាបង្ហាញហើយដែរ។ តើលោកប្រធានចង់ឲ្យខ្ញុំបង្ហាញនៅលើសំណួរទាក់ទងនឹងបញ្ហាណាមួយណាទៀតលោកប្រធាន?

[១១:១៥:៣៣]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាគប្បីស្តាប់នូវមតិជំទាស់របស់គេ។ ពីមុនលោកបានលើកឡើងថាលោកមានបំណងថាចង់ឆ្លើយតបទៅនឹងសេចក្តីជំទាស់ ដើម្បីឲ្យអង្គជំនុំជម្រះមានមូលដ្ឋានពិចារណាសម្រេចលើសេចក្តីជំទាស់របស់ភាគីម្ខាងទៀត។ សំណួរសួរថាតើលោកឆ្លើយតបដែរឬទេ លើបញ្ហា

សេចក្ដីជំទាស់។ លោកត្រូវក្ដាប់ឲ្យបានលើបញ្ហាសេចក្ដីជំទាស់លើសំណួររបស់លោកសួរ ហើយនិងសេចក្ដីជំទាស់របស់ភាគី ហើយលោកឆ្លើយតប ឬក៏មិនឆ្លើយតប ដើម្បីឲ្យយើងជាអង្គជំនុំជម្រះហ្នឹងសម្រេច ថាតើឲ្យឆ្លើយ ឬក៏មិនចាំបាច់ឆ្លើយទេ។ មូលហេតុសំណួរហ្នឹង វាស្ថិតក្នុងប្រភេទសំណួរទីប៉ុន្មាន ឬក៏សំណួរប្រភេទណាដែលច្បាប់ហាមឃាត់មិនឲ្យសួរ ឬក៏បដិសេធនូវការជំទាស់ ដើម្បីឲ្យសាក្សីឆ្លើយតបទៅនឹងសំណួរដែលលោកសួរ។ នេះគឺជានីតិវិធីដែលយើងអនុវត្តកន្លងមក ៦ឆ្នាំហើយ។

[១១:១៦:៤០]

**លោក ខេល លីសាក់៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

មិនមានការបកប្រែទេ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយខាងអង្គភាពបកប្រែភាសា។

**លោក ខេល លីសាក់៖**

លោកប្រធាន អ្វីដែលខ្ញុំចង់និយាយនេះ គឺជាការអនុវត្តដែលបានកំណត់តាំងពីសវនាការលើកដំបូងដែលត្រូវតាំងសំណួរទៅកាន់សាក្សី គឺដោយយើងយកចម្លើយរបស់សាក្សីផ្សេងយកមកសួរសាក្សីរូបនេះ ហើយការធ្វើបែបនេះគឺថាត្រូវបានសាក -- ក៏ខាងមេធាវីការពារក្ដីក៏បានធ្វើការតាំងសំណួរបែបនេះផងដែរ។ ទាក់ទងទៅនឹងរបបអាហារ សាក្សីបានសួររួចមកហើយ ហើយសាក្សីក៏បានឆ្លើយជំនួសទៅនឹង -- ឆ្លើយទាក់ទងទៅរបបអាហារ ពាក់ព័ន្ធទៅនឹងម្ដាយរបស់គាត់។ ដូច្នេះ នីតិវិធីនៃការសួរសំណួររបស់មនុស្សម្នាក់ទៀត យកមកសួរសាក្សីនេះដោយផ្ទាល់ ដោយយើងយកព័ត៌មានដែលសាក្សីរូបនេះជាអ្នកឆ្លើយនោះទេ។ ដូច្នេះការអនុវត្តបែបនេះ គឺមានកន្លងរួចមកហើយ។

[១១:១៨:១៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

សុំលើកក្រោយ សូមជំទាស់តែម្ដងបានហើយ ដើម្បីអ្នកឆ្លើយតប គេឆ្លើយតប ដើម្បីពន្លឿននៃកិច្ចដំណើរការនីតិវិធី។ មិនជំទាស់សា ត្រឡប់ចុះ ត្រឡប់ឡើងទេ។ លើកនេះយើងអនុញ្ញាត លើកក្រោយមិនអនុញ្ញាតដូច្នេះទៀតឡើយ។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំយល់លោកប្រធាន ក៏ប៉ុន្តែខ្ញុំត្រូវតែត្រឡប់បកក្រោយ ប្រឆាំងនឹងការបំភ្លឺរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពីព្រោះការប្រើចម្លើយរបស់សាក្សីម្នាក់ទៀតនោះមិនមែនជាការលំបាកអ្វីនោះប៉ុន្មាននោះទេ មិនមែនជាបញ្ហាអ្វីទេ ក៏ប៉ុន្តែត្រូវតែបង្កើតជាមូលដ្ឋានសិនមុននឹងចោទសំណួរ និយាយប្រាប់ទៅ -- ឧទាហរណ៍អំមិញនេះនិយាយទៅប្រាប់សាក្សីថា "អ៊ូ! ម្តាយលោកហ្នឹងបាននិយាយយ៉ាងដូច្នេះ" អ៊ីចឹងគឺយើងមិនដឹងថា ឯកសារណាជាឯកសារណី ហើយមិនដឹងថាយកចម្លើយរបស់អ្នកណា អ្នកណី អ៊ីចឹងហើយបានខ្ញុំថា សំណួរដែលគាត់សួរឡើងអម្បាញ់មិញនេះ វាអត់មានមូលដ្ឋាន មិនបង្កើតជាមូលដ្ឋានសិន មុននឹងចោទសំណួរ។ បើសិនជានៅ -- បើនិយាយថានៅក្នុងវគ្គមួយ ការជម្រះសេចក្តីវគ្គមួយនោះគឺថាត្រូវតែបង្ហាញពីបរិបទឲ្យច្បាស់លាស់ មូលដ្ឋានឲ្យច្បាស់លាស់មុននឹងចោទសំណួរទៅសាក្សី។ ដូច្នេះអ៊ីចឹងហើយ ដូចជាភស្តុតាងជាក់ស្តែងអម្បាញ់មិញហ្នឹង យើងមិនដឹងថាគាត់និយាយអំពីឯកសារណាផងអម្បាញ់មិញនេះ។ អ៊ីចឹងយើងត្រូវតែគោរពពីនីតិវិធីនេះឲ្យបានច្បាស់លាស់ បង្កើតជាមូលដ្ឋានបរិបទឲ្យច្បាស់លាស់សិន។

[១១:២០:១១]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីការពារក្តីមិនមានប្រសិទ្ធភាព។ សាក្សីត្រូវឆ្លើយនឹងសំណួរនេះ ហើយករណីសាក្សីដែលមិនទំនងជាមិនចាំនូវសំណួរទេ។ សូមតំណាងសហព្រះរាជអាជ្ញារៀបចំនូវសំណួរសាជាថ្មីដើម្បីសួរបញ្ជាក់ទៅគាត់ គឺតំណាងសហព្រះរាជអាជ្ញាជាតិបានឆ្លើយ បានបង្ហាញឯកសារ និងបរិបទដែលពាក់ព័ន្ធនឹងសំណួរនេះយ៉ាងច្បាស់លាស់ ក្រែងបារម្ភ ក្រែងលោកវាមានបញ្ហាបកប្រែភាសា ខ្ញុំមិនដឹង ប៉ុន្តែចៅក្រមជាតិ ចៅក្រមអន្តរជាតិក៏បានយល់ដូចខ្ញុំដែរ គឺបរិបទនេះគឺខាងសហ តំណាងសហព្រះរាជអាជ្ញាជាតិបានបង្ហាញច្បាស់លាស់ហើយបរិបទនៃឯកសារដែលពាក់ព័ន្ធនឹងសំណួរ ហើយសំណួរបែបនេះ គឺអាចសួរបាន ពីព្រោះអង្គជំនុំជម្រះបានបញ្ជាក់រួចហើយ ថាសាក្សីគឺឆ្លើយនូវសំណួរណាដែលខ្លួនបានដឹង បានឮ បានឃើញ បានចងចាំ បានសង្កេត ឬក៏មានបទពិសោធន៍ផ្ទាល់ផ្លូវកាត់ដោយផ្ទាល់។ នេះជា យើងបានបង្ហាញច្បាស់លាស់ឆ្លងកាត់បទពិសោធន៍នៃការសវនាការរឿងក្តី៦ឆ្នាំនេះ គឺយើងបានដកបទពិសោធន៍នេះ ហើយយើងបានកំណត់នូវវិធាននៃការដោះស្រាយបញ្ហានេះកន្លងមកគឺបានច្បាស់លាស់ហើយ មិនដែលមានបញ្ហាអ្វីទេ។

សូមអញ្ជើញ!

**លោក សេង លាង៖**

លោកប្រធាន ដើម្បីជាកិច្ចងាយស្រួល ខ្ញុំសុំការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញឯកសារស្តីអំពីកិច្ចសម្ភាសន៍នេះ ដែលខ្ញុំនឹងសួរក្នុងពេលខាងមុខនេះ ជូនដល់លោកសាក្សី។ តើលោកអនុញ្ញាតដែរទេ លោកប្រធាន? ឯកសារលេខ D25/30។

**ប្រធានអង្គជំនុំ៖**

លោកអាចបង្ហាញធ្វើជាមូលហេតុសំអាងនៃបរិបទដែលលោកសួរពាក់ព័ន្ធបាន ប៉ុន្តែលោកមិនអាចបង្ហាញឯកសារនោះទៅសាក្សីបានទេ។

**លោក សេង លាង៖**

អរគុណលោកប្រធាន។

**សួរដោយលោក សេង លាង៖**

**ស៖** អ៊ីចឹង ខ្ញុំសូមរំឭកសំណួររបស់ខ្ញុំឡើងវិញ ដើម្បីឲ្យងាយនឹងយល់។ នៅក្នុងកិច្ចសម្ភាសន៍មួយរបស់ម្តាយរបស់លោកជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតគឺនៅក្នុងឯកសារលេខD25/30 ត្រង់ ERN ជាភាសាអង់គ្លេស 00223487, ERN ជាភាសាខ្មែរ 00163504, ERN ជាភាសាបារាំង 00178423 ម្តាយរបស់លោកបាននិយាយថា៖ "ដោយសារធ្វើបាយរួមហូបមិនឆ្អែត ហើយនិយាយថាគ្មានកម្លាំងធ្វើការ" និងថា "ពេលដែលម្តាយរបស់លោកនិយាយអំពីបញ្ហាហូបមិនឆ្អែត ពួកគាត់បានកត់ត្រាទុក"។ តើលោកមានដឹងអំពីបញ្ហានេះដែរឬទេ លោកសាក្សី?

[១១:២៣:១១]

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំបាទ ខ្ញុំគ្រាន់តែបានដឹងខ្លះៗ ប៉ុន្តែខ្ញុំអត់យកចិត្តទុកដាក់ទេរឿងហ្នឹង។ ខ្ញុំសូមឲ្យតុលាការបន្តទៅសួរជុំវិញពីគុកក្រាំងតាចាន់។ កុំបាច់និយាយនូវមូលហេតុតាមសហករណ៍ ព្រោះខ្ញុំអត់យកស្វរចិត្តទុកដាក់ទេ គឺតាមសហករណ៍។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនអាចតម្រង់កំណត់ខ្លួនឯងចង់ឲ្យភាគីពាក់ព័ន្ធសួរកន្លែងណាក៏បាននោះទេ។ សាក្សីស្តាប់នូវសំណួរដែលភាគីសួរ។ សាក្សីត្រូវឆ្លើយចំពោះសំណួរនោះ ប្រសិនបើលោកមិនដឹងទេ លោក

ឆ្លើយថាមិនដឹង នោះជានីតិវិធី។ មិនមែនលោកចង់ឆ្លើយត្រង់ណាក៏បាន ស្រាប់តែចិត្តរបស់លោកនោះទេនៅក្នុងនីតិវិធីចំពោះមុខតុលាការ។ ស្តាប់សំណួរភាគីឲ្យច្បាស់ ឆ្លើយតបនឹងសំណួរច្បាស់លាស់ដែលភាគីបានសួរ។ ក្នុងករណីសំណួរមិនច្បាស់ អាចសុំឲ្យបញ្ជាក់សំណួរនោះសាជាថ្មីម្តងទៀត។

**សួរដោយលោក សេង លាង៖**

**ស៖** តើលោកមានដឹងថាតើម្តាយរបស់លោកបានរាយការណ៍អំពីបញ្ហាហូបមិនឆ្អែតនេះទៅកាន់អ្នកណាគេដែរឬទេ?

[១១:២៤:៣៩]

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំគ្រាន់បានដឹងថា គាត់និយាយជាមួយបងប្អូនញាតិមិត្ត អ្នកសហករណ៍ជាមួយគ្នា ប៉ុន្តែអត់ដឹងរឿងគេ អ្នកកត់ត្រាអត់ដឹង ព្រោះគេមានអ្នកស៊ើបអង្កេតខាងក្រៅ ព្រោះគាត់និយាយជាមួយគ្នាគាត់អ្នកហាន់បន្លែ គាត់ហែកដើមចេកស្ងោរអ៊ីចឹងទៅ គាត់និយាយៗវាមានគេអ្នកដែលចាំស្តាប់ មានអ្នកបង្កប់ខ្លួននៅក្នុងហ្នឹង។ ខ្ញុំអត់ដឹង ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** តើលោកមានដឹងទេថាតើម្តាយរបស់លោកមានស្ថានភាពរបៀបណានៅក្នុងកំឡុងពេលដែលគាត់រស់នៅក្នុងសហករណ៍ហ្នឹង? តើគាត់មានសុខភាពល្អដែរឬទេ?

**ឆ៖** កាលនោះម្តាយខ្ញុំគាត់កំពុងតែកូនខ្ចីបានមួយខែ គាត់សុខភាពគាត់អត់សូវស្រួល គាត់ហែវគាត់ហត់ គាត់ឈឺផងអីផង។

**ស៖** ឥឡូវខ្ញុំ បន្តសំណួរខ្ញុំទៅកាន់ប្រធានបទថ្មីមួយទៀត ពាក់ព័ន្ធជាមួយនឹងការប្រព្រឹត្តចំពោះប្រជាជនថ្មីវិញម្តង។ សំណួរសួរថាតើជនភៀសខ្លួនពីភ្នំពេញ ឬក៏ពីទីក្រុងផ្សេង ឬទីប្រជុំជនផ្សេងត្រូវបានគេបញ្ជូនទៅស្រុកត្រាំកក់នៅក្រោយថ្ងៃ១៧ ខែមេសា ឬក៏នៅថ្ងៃ១៧មេសា -- ១៧ ខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ?

**ឆ៖** ចំណែកប្រជាជនថ្មី ខ្ញុំប្រជាជនចាស់ ខ្ញុំដឹងតែគេជម្លៀសមកតាមមូលដ្ឋានហើយគេបែងចែកទៅតាមកងថ្មី កងចាស់ផ្សេងៗពីគ្នា។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** តើលោកមានដឹងថាប្រជាជនថ្មីដែលទើបជម្លៀសមកដល់ស្រុកត្រាំកក់របស់លោកហ្នឹងគេសម្គាល់ថាជាប្រជាជនយ៉ាងដូចម្តេចដែរ?

[១១:២៧:៤០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា តំណាងសហព្រះរាជអាជ្ញាគួរគិតថានៅពេលនោះសាក្សីមានអាយុតែ១៥ឆ្នាំទេ គឺថាតំណាងសហព្រះរាជអាជ្ញាអាចសួរតែអ្វីដែលគាត់បានឃើញ បានដឹង បានឮ។ ការតាំងសំណួរទូទៅដូចជាការប្រព្រឹត្តមកលើប្រជាជនថ្មីជាដើមនេះ គឺថាវាទូលំទូលាយណាស់ ដូច្នេះខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះមេត្តាបង្គាប់ ណែនាំទៅដល់តំណាងសហព្រះរាជអាជ្ញាតាំងសំណួរណាឲ្យបានជាក់លាក់ដែលអាចសាក្សីអាចដឹងបាន។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាបន្តសំណួររបស់លោកទៀតចុះ! ការកត់សម្គាល់ដូច្នេះមិនចាំបាច់ទេ។

**សួរដោយលោក សេង លាង៖**

**ស៖** សូមលោកជួយបញ្ជាក់មើល៍ ថាតើប្រជាជនដែលទើបជម្លៀសមកដល់ស្រុកត្រាំកក់ហ្នឹង គេហៅសម្គាល់ថាជាប្រជាជនយ៉ាងដូចម្ដេចដែរ?

**លោក មាស សុខា៖**

**ឆ៖** គេជម្លៀសប្រជាជនថ្មីមកតាមមូលដ្ឋាន គេសម្គាល់ថាប្រជាជន១៧មេសា ហើយគេនិយាយថា ពួករាជការ មន្ត្រីរាជការលន់នល់។

**ស៖** អរគុណលោកសាក្សី។ តើលោកអាចបញ្ជាក់បានទេថាតើគ្រួសាររបស់លោកហ្នឹងត្រូវបានចាត់ទុកថាជាប្រជាជន១៧មេសា ដែរឬទេ?

**ឆ៖** ខ្ញុំមិនមែនប្រជាជន១៧មេសាទេ ព្រោះប្រជាជននៅតាមមូលដ្ឋានតាំងពីសម័យមុន អត់ដែលទៅនៅក្នុងមន្ត្រីរាជការណាទេ នៅតែក្នុងភូមិស្រែគ្រួ តាំងពីអង្គាល់ណាខ្ញុំឃើញនៅតែហ្នឹងដែរ ខ្ញុំអត់ដឹងទៅណា នៅទីណា អត់ដឹង។

**ស៖** តើលោកដឹងទេថា -- គេបែងនៅៗក្នុងរបបគ្រប់គ្រងរបស់ខ្មែរក្រហមហ្នឹង គេមានបែងចែកប្រជាជនជាប៉ុន្មានក្រុម?

[១១:៣០:២៥]

**ឆ៖** គេបែងចែកប្រជាជនមានបីប្រភេទ។ មានត្រៀម មានផ្ញើ មានពេញសិទ្ធិ។

**ស៖** តើលោកអាចប្រាប់បានទេ ថាតើរវាងប្រជាជនចាស់ និង ប្រជាជនថ្មី តើការហូបចុក ការរស់ស្នាក់នៅ និងការធ្វើការងារហ្នឹង តើគេឲ្យធ្វើរួមគ្នារវាងប្រជាជនចាស់ និងប្រជាជនថ្មី ឬក៏ដាច់ដោយឡែកពីគ្នា?

**ឆ៖** ប្រជាជនថ្មី ចាស់ គេធ្វើការ ខ្លះគេបានធ្វើជាមួយគ្នា ខ្លះគេធ្វើដោយឡែក ខ្លះរួមកម្លាំងគ្នាទៅ អ្នកថ្មីក៏ដូចជាអ្នកចាស់ ព្រោះអ្នកចាស់ខ្លះគេថាអ្នកមូលធន អ្នកមានសក្តិភូមិអីចឹង គេឲ្យបញ្ចូលគ្នាជាមួយពួកថ្មីទៅ។

**ស៖** តើលោកមានបានដឹងទេថាតើប្រជាជនថ្មីដែលគេជម្លៀសមកកាន់ស្រុកត្រាំកក់ហ្នឹងមានប្រហែលជាប៉ុន្មានគ្រួសារដែរ?

**ឆ៖** ខ្ញុំបាទ ខ្ញុំអត់ដឹងទេរឿងនេះ រឿង--

**ប្រធានអង្គជំនុំ៖**

ឈប់ៗសិន!

សូមអញ្ជើញ លោក កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណជាថ្មីម្តងទៀត សាក្សីរូបនេះគឺថាមានអាយុតែដប់ប្រាំឆ្នាំទេ ដូចខ្ញុំបានបញ្ជាក់អីចឹង ការសួរសំណួរបែបនេះ គឺជាការសួរឲ្យសាក្សីឆ្លើយស្មានៗតែប៉ុណ្ណោះ។ ខ្ញុំសូមជំទាស់នឹងសំណួរនេះ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់គ្មានប្រសិទ្ធភាព។ លោកព្រះរាជអាជ្ញាអាចតសំណួរសួរដល់សាក្សីរូបនេះបន្តទៀត។

**សួរដោយលោក សេង លាង៖**

សំណួរអម្បាញ់មិញ ខ្ញុំសុំឲ្យលោកជួយបញ្ជាក់មុននឹងខ្ញុំឆ្លងទៅប្រធានបទមួយទៀត។ គឺថាតើមានប្រជាជនថ្មី -- ខ្ញុំៗ -- ដើម្បីជាផលប្រយោជន៍នៃពេលវេលា ខ្ញុំសូមឆ្លងទៅកាន់ប្រធានបទថ្មីមួយទៀតពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះព្រះពុទ្ធសាសនា។

**ស៖** នៅចន្លោះខែមេសា ឆ្នាំ១៩៧៥ និងខែមករា ឆ្នាំ១៩៧៩ តើគេមានអនុញ្ញាតឲ្យប្រជាជននៅស្រុកត្រាំកក់របស់លោកហ្នឹង គោរពព្រះពុទ្ធសាសនាដែរឬទេ?

**លោក មាស សុខា៖**

**ឆ៖** ចំណែកព្រះពុទ្ធសាសនាវិញខ្ញុំសម្លឹង និងសង្កេតឃើញតាំងពីឆ្នាំ៧៣ រហូតដល់ឆ្នាំ៧៤។ ដល់៧៤ គេប្រើលោកសង្ឃដឹកមាន់ ដឹកទា យកមកវាយសង្គ្រាមនៅទីក្រុងភ្នំពេញ ហើយដល់ចន្លោះឆ្នាំ ៧៥ ខ្ញុំមិនដែលឃើញមានអ្នកណាគោរពបូជាព្រះពុទ្ធសាសនាទេ។

**ស៖** តើលោកមានដឹងថាតើមានអ្វីកើតឡើងចំពោះព្រះសង្ឃនិងវត្តនានានៅក្នុងស្រុកត្រាំកក់ នៅក្នុងអំឡុងពេលនោះដែលឬទេ?

[១១:៣៣:៥៨]

**ឆ៖** ខ្ញុំគ្រាន់តែដឹងថាគេឲ្យផ្សឹកលោក អត់ឲ្យមានលោក គេយកវត្តដាក់ទីតាំងពេទ្យ ដាក់ទីតាំង ចិញ្ចឹមជ្រូក ឬដាក់ធ្វើជាគុកតែប៉ុណ្ណឹងទេ។ រឿងលោកសង្ឃគេផ្សឹកចេញប៉ុណ្ណឹងទេ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍មួយរបស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រង់ឯកសារ D25/31, ត្រង់ ERN ជាភាសាអង់គ្លេស 00223495, ERN ជាភាសាខ្មែរ 00163512, ERN ជាភាសាបារាំង 00178112។ លោកបាននិយាយដូចតទៅ៖ “វត្តនៅជិតភូមិរបស់យើងត្រូវបាន គេរុះរើ ហើយរូបសំណាកព្រះពុទ្ធត្រូវបានគេយកទៅកប់។ មានវត្តពីរនៅជិតភូមិអស់លោក គឺវត្ត មឿងថា ត្រូវបានប្រែក្លាយទៅជាមន្ទីរពេទ្យ និងវត្តអង្គបក្សីត្រូវបានប្រែក្លាយទៅជាសហករណ៍។ ពួក គេគ្រាន់តែរុះរើដំបូលតែប៉ុណ្ណោះ”។ សំណួរសួរថាតើនៅក្នុងស្រុកត្រាំកក់ តើនៅពេលណាទើបវត្ត ត្រូវបិទទ្វារ ហើយនិងពេលណាព្រះសង្ឃត្រូវបានគេផ្សឹក?

**ឆ៖** នៅពេលឆ្នាំ៧៥ គឺលោកសង្ឃត្រូវផ្សឹកគ្រប់ទីកន្លែងទាំងអស់។

**ស៖** តើលោកមានដឹងទេថា តើមានព្រះសង្ឃដែលបដិសេធមិនព្រមសឹកដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសុំបន្តធ្វើការជំទាស់តទៅទៀតលោកប្រធាន។ តើធ្វើម៉េចបានជាសាក្សីរូបនេះអាចនឹងដឹងថា ព្រះសង្ឃគ្រប់អង្គត្រូវបានគេដោះស្បង់ចីពរ គេផ្សឹកយ៉ាងដូច្នេះ? ជួនកាល -- ខ្ញុំៗអាចនឹងសុំជំទាស់រៀង រាល់ពេល ពីព្រោះជាការសួរឲ្យសាក្សីឆ្លើយស្មានៗដដែលបាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ តំណាងសហព្រះរាជអាជ្ញាអញ្ជើញបន្តសំណួរទៀត!

**សួរដោយលោក សេង លាង៖**

**ស៖** លោកសាក្សី ខ្ញុំគ្រាន់តែចង់ឲ្យលោកបញ្ជាក់ឲ្យបានច្បាស់អំពីឃុំរបស់លោកទេ គឺនៅក្នុងឃុំជាងទងរបស់លោកនោះ។ តើព្រះសង្ឃ មានព្រះសង្ឃណាដែលគាត់បដិសេធមិនព្រមសឹកដែរឬទេ?

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំអត់បានដឹងទេ រឿងលោកបដិសេធមិនព្រមសឹក ព្រោះខ្ញុំអត់ដឹង។ ខ្ញុំដឹងតែលោកពោធិវង្ស នន្ទ ង៉ែត មួយលោកអត់ព្រមសឹក។

**លោក សេង លាង៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន នៅពេលនេះ ខ្ញុំបាទបញ្ចប់សំណួរខ្ញុំត្រឹមនេះ ហើយខ្ញុំទុកឱកាសនេះដល់សហការីរបស់ខ្ញុំគឺលោក ឌេល នឹងសួរសំណួរបន្តទៅទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ សហព្រះរាជអាជ្ញារងអន្តរជាតិ។

[១១:៣៧:៤៨]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោក មាស សុខា! ខ្ញុំឈ្មោះ ឌេល លីសាក់។ ខ្ញុំគឺជាតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខ្ញុំសុំសំណួរទៅលោកទាក់ទងទៅនឹងការចាប់ខ្លួនសមាជិកក្រុមគ្រួសាររបស់លោក ហើយនិងការឃុំខ្លួនពួកគាត់នៅមន្ទីរសន្តិសុខក្រាំងតាចាន់។ ខ្ញុំសុំសួរសំណួរដំបូងពាក់ព័ន្ធទៅនឹងកាលៈទេសៈដែលវានាំឲ្យមានការចាប់ខ្លួនសមាជិកគ្រួសាររបស់លោក។ លោកបានឆ្លើយថា នៅក្នុងកិច្ចសម្ភាសន៍របស់សហចៅក្រមស៊ើបអង្កេតគឺ D25/31 ខ្មែរ 0016 --, អង់គ្លេស 00223496, បារាំង 001781 12 ដែលនៅក្នុងខែមិថុនា ឆ្នាំ១៩៧៦។ ខ្ញុំសុំដកស្រង់៖ “សមាជិកគ្រួសាររបស់ខ្ញុំត្រូវបានចាប់ខ្លួន និងយកទៅឃុំឃាំងនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ ដំបូងគេចាប់ឪពុកខ្ញុំ”។ សំណួរដំបូងរបស់ខ្ញុំសួរថាតើសមាជិកគ្រួសាររបស់លោកប៉ុន្មាននាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅក្នុងខែមិថុនា ឆ្នាំ១៩៧៦នោះ?

**លោក មាស សុខា៖**

**ឆ៖** ខ្ញុំឆ្លើយតាមសំណួររបស់តុលាការ ព្រោះឪពុកខ្ញុំគេចាប់ពីឆ្នាំ៧៦ ខែ៦។ ព្រោះមូលហេតុគេដឹកនាំឲ្យគាត់ធ្វើជាមេខ្មែរក្រហមពីឆ្នាំ៦១។ នៅឆ្នាំចន្លោះ៦១មក គឺសម័យឥស្សរៈ ហើយបន្ទាប់មកគាត់ដល់ឆ្នាំ៧៦ គាត់ក៏ប្រឆាំងនឹងគេរឿងហូបបាយមិនឆ្អែត ព្រោះគេថាគាត់អ្នកក្បត់នឹងសហករណ៍។

[១១:៤០:00]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំនឹងសួរមូលហេតុដែលនាំឲ្យមានការចាប់ខ្លួនសមាជិកគ្រួសាររបស់លោក។ សំណួរដំបូងគ្រាន់តែសួរថាតើសមាជិកគ្រួសាររបស់លោកប៉ុន្មាននាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៦នោះ?

**ឆ៖** ក្រុមគ្រួសារខ្ញុំ ខ្មែរក្រហមចាប់ខ្លួនចំនួន ១២នាក់។

**ស៖** តើលោកអាចជ្រាបជូនអង្គជំនុំជម្រះបានទេក្នុងចំណោមអ្នកទាំង១២នាក់ហ្នឹង តើជាអ្នកណាខ្លះ? ជាសាច់ញាតិជិតឆ្ងាយយ៉ាងដូចម្ដេចខ្លះ ជូនអង្គជំនុំជម្រះឲ្យបានជ្រាប។

**ឆ៖** បងប្អូនខ្ញុំបង្កើតអត់មានអ្នកដទៃ។ មានតែបងថ្លៃមួយអ្នកសាច់ក្រៅ ប៉ុន្តែរួមជាមួយហ្នឹងមាន១២នាក់ បងប្អូនបង្កើតនិងបងថ្លៃហ្នឹង និងឪពុក។

**ស៖** តើបងប្អូនប្រុសស្រីបង្កើតរបស់លោកប៉ុន្មាននាក់ដែលត្រូវខ្មែរក្រហមចាប់ខ្លួន?

**ឆ៖** បងប្អូនខ្ញុំបង្កើតមានប្រាំបីនាក់ ម្ដាយ -- បងប្អូនបង្កើតប្រាំបីនាក់។

**ស៖** តើបងប្អូនបង្កើតទាំងប្រាំបីនាក់ហ្នឹងត្រូវបានខ្មែរក្រហមចាប់ខ្លួន ឬមានតែប៉ុន្មាននាក់ក្នុងចំណោមប្រាំបីនាក់ត្រូវបានគេចាប់ខ្លួន?

**ឆ៖** ចាប់ខ្លួនរួមជាមួយទាំងឪពុក។ ឪពុកគេយកទៅមុន ហើយនិងបងថ្លៃ។ ក្រោយយកបងស្រីខ្ញុំ និងប្អូនៗប្រាំពីរនាក់និងបងស្រី ហើយនិងក្មួយទាំងអស់ហ្នឹង វាបូករួមទាំងអស់ជាមួយគ្នាមាន១២នាក់។

**ស៖** តើបងប្អូនបង្កើតដែលគេចាប់ខ្លួនហ្នឹងប៉ុន្មាននាក់ជាបងរបស់លោក ហើយប៉ុន្មាននាក់ដែលមានអាយុប្អូនលោក?

**ឆ៖** ប្អូនលោក -- ប្អូនខ្ញុំមានប្អូននាក់ពីខាងក្រោម ក្មួយ -- កូនង៉ែតពីរ កូនបងខ្ញុំមួយ ហើយកូនម្ដាយខ្ញុំមួយវាអត់ទាន់ដឹងក្ដី អាតូចជាងគេនៅទារកពីរនាក់ ហើយក្មួយខ្ញុំបង្កើតគឺកូនបងស្រីខ្ញុំមួយ ហើយប្អូនៗខ្ញុំប៉ុន្មានបីប្អូននាក់ទៀត -- បីនាក់ទៀត។

[១១:៤៣:១៣]

**ស៖** ចុះកូនរបស់បងស្រីរបស់លោកហ្នឹងអាយុប៉ុន្មានអង្កាល់នុ៎ង?

**ឆ៖** កូនស្រីបងខ្ញុំ អាបងគេអាយុបី ឬបួនឆ្នាំ ហើយកូនតូចមួយអាយុពីរខែ។

**ស៖** សូមអរគុណលោកសាក្សី។ នៅក្នុងចម្លើយរបស់លោកឆ្លើយជូនសហចៅក្រមអង្កេតត្រង់ទំព័រសូន្យ ERN 00663513, អង់គ្លេស 003496, បារាំង 00178112។ លោកបានឆ្លើយថា មានភូមិប្រាំនាក់ទៀត គឺប្អូនពេញវ័យ ម្នាក់ជាកុមារក៏បានចាប់ខ្លួនជាមួយក្រុមគ្រួសាររបស់លោកដែរ។ តើអ្នកភូមិទាំងអស់នេះជាអ្នកភូមិមកពីភូមិរបស់លោកតែម្តង ដែលត្រូវចាប់ខ្លួនដំណាលគ្នានឹងក្រុមគ្រួសារលោកនោះ?

**ឆ៖** នៅក្នុងភូមិជាគ្នា សាច់ញាតិជាមួយគ្នាដែរ មិនមែនអ្នកដទៃឆ្ងាយពីគ្នាទេ ត្រូវបងប្អូនដែរ។

**ស៖** តើលោកចាំឈ្មោះអ្នកណាខ្លះនៅក្នុងចំណោមអ្នកភូមិប្រាំនាក់ហ្នឹងទេ?

**ឆ៖** ខ្ញុំគ្រាន់តែដឹងឈ្មោះ។ ឈ្មោះ ១) ប៊ិន, ២) ទោ, ៣) យាយស៊ិន, ៤) អាហួត, ៥) អាហេង, ៦) ឪពុកវាឈ្មោះ ហួន។ ហ្នឹងគេយកទៅមុនដែរ ឆ្នាំ៧៤។

**ស៖** លោកប្រធាន នៅពេលនោះគឺមានសាក្សីម្នាក់ទៀតមកពីភូមិស្វាយគ្រួ ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតសម្ភាសដែរ។ ហើយសាក្សីនោះ គឺមានឈ្មោះហៅក្រៅ មាន១ -- ខ្ញុំ១ចង់សួរសាក្សីរូបនេះ ថាតើគាត់ស្គាល់សាក្សីដែលសហចៅក្រមស៊ើបអង្កេតសាកសួរនោះដែរឬទេ ដើម្បីចង់ដឹងថាតើគាត់ស្គាល់បុគ្គលរូបនោះទេ? ខ្ញុំនៅពេលនោះគឺ ខ្ញុំនឹងស្នើសុំអង្គជំនុំជម្រះ គឺថាប្រើឈ្មោះរបស់សាក្សីតែម្តង ដោយមិនប្រើឈ្មោះសម្ងាត់របស់សាក្សីរូបនោះទេ។ ចង់ដឹងដំបូងថាតើសាក្សីរូបនេះគាត់ស្គាល់បុគ្គលរូបនោះដែរឬក៏អត់?

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកចៅក្រម ហ្វេនស៍!

[១១:៤៧:២០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមានសំណួរតែមួយទេ។ តើតំណាងសហព្រះរាជអាជ្ញា លោកមានបំណងអីដែលចង់យកកំណត់ហ្នឹងមកបង្ហាញជូនសាក្សីរូបនេះ? ហើយចង់ប្រើប្រាស់ឈ្មោះហ្នឹង?

**លោក ឌេល លីសាក់៖**

បើសិនណាៗជាអនុញ្ញាតឲ្យប្រើឈ្មោះតែម្តង ខ្ញុំនឹងចាប់ផ្តើមតែម្តង ហើយនិងបង្ហាញជូនក្នុងឯកសារនេះ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះឲ្យលោកសហព្រះរាជអាជ្ញាប្រើឈ្មោះពេញលេញរបស់សាក្សីទៅចុះ ដោយសារសាក្សីនោះបានទទួលមរណភាពហើយ។

[១១:៤៨:២៧]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ការិយាល័យសហចៅក្រមស៊ើបអង្កេតបានសម្ភាសបុគ្គលម្នាក់ទៀតមកពីភូមិស្វាយគ្រួ គាត់ឈ្មោះ សុក។ លោកស្គាល់មនុស្សម្នាក់ឈ្មោះ សុក ឬ សុត នេះដែរទេ មកពីភូមិស្វាយគ្រួដែរ?

**លោក មាស សុខា៖**

**ឆ៖** ស្គាល់។ គាត់ជាមេភូមិសព្វថ្ងៃ ប៉ុន្តែគាត់ស្លាប់ហើយ – សុក សុត។

**ស៖** តើលោក សុក សុត គឺជាមនុស្សម្នាក់ដែលត្រូវគេចាប់ខ្លួននៅក្នុងពេលនុង់ជាមួយនឹងសមាជិកគ្រួសាររបស់លោកដែរឬទេ?

**ឆ៖** សុក សុត គឺគេចាប់ជាមួយខ្ញុំដែរ ជាមួយបងគាត់ម្នាក់ទៀតឈ្មោះ សុក សាន។ ហើយបន្ទាប់ទៀតឈ្មោះ សឿ សុមើ ហើយបន្ទាប់មក សួន យ៉ា។

**ស៖** លោកបាននិយាយយោងពីខាងដើមរួចមកហើយ ប៉ុន្តែខ្ញុំសូមសួរលោកថា តើលោកអាចជម្រាបជូនតុលាការបានទេ ថាហេតុអ្វីបានជាខ្មែរក្រហមចាប់ឪពុកម្តាយសមាជិកគ្រួសាររបស់លោកនៅក្នុងខែមិថុនា ឆ្នាំ១៩៧៦?

[១១:៥០:១៤]

**ឆ៖** មូលហេតុគេចាប់ឪពុកខ្ញុំ គេបានប្រាប់បងថ្លៃខ្ញុំថា ឲ្យបងថ្លៃខ្ញុំធ្វើជាមីទ្ទិងផ្តិតមេដៃទម្លាក់

មេភូមិឲ្យចេញ ហើយរើសជាមេភូមិថ្មី ប្រធានសហករណ៍ថ្មី សម្រាប់ប្រជាជន ដើម្បីប្រជាជនរស់នៅបានស្រួល។ ហើយបន្ទាប់មកគេឲ្យបងខ្ញុំធ្វើមីទិ្ទងផ្តិតមេដៃហើយ ក៏ប្រជាជនខ្លះផ្តិតមេដៃធ្វើការហ្នឹងហើយ គេឲ្យបងខ្ញុំយកលិខិតហ្នឹងឲ្យទៅគេ ក៏គេចាប់ខ្លួនបងខ្ញុំ ចាប់បាត់ខ្លួនទៅតែម្តង។ ថ្ងៃស្អែកឡើងគេបានមកចាប់ឪពុកខ្ញុំបន្តទៅទៀត វេលាម៉ោងមួយរសៀល ខែ៦ហ្នឹង ខ្ញុំអត់ចាំថ្ងៃ។

**ស៖** តើកិច្ចប្រជុំដែលលោកថា គឺប្រមូលប្រជាជនដើម្បីផ្តិតមេដៃហ្នឹង តើលោកចង់មានន័យថាផ្តិតមេដៃហ្នឹង គឺជាទម្រង់មួយនៃការបោះឆ្នោតដើម្បីទម្លាក់មេភូមិ ទម្លាក់មេសហករណ៍ហ្នឹង ឬយ៉ាងម៉េច?

**ឆ៖** ទម្លាក់មេសហករណ៍ មេភូមិហ្នឹងតែម្តង។ គេឲ្យលិខិតមកបងថ្លៃខ្ញុំហ្នឹងតែម្តង ឲ្យថាប្រមូលប្រជាជនមកធ្វើមីទិ្ទងផ្តិតមេដៃទម្លាក់ភូមិហ្នឹងចោល កុំទុក។

**ស៖** តើប្រធានសហករណ៍ដែលគេត្រូវផ្តិតមេដៃទម្លាក់ហ្នឹងឈ្មោះអីដែរ?

**ឆ៖** ឈ្មោះ អួន ណុប នៅភូមិស្រែគ្រូ។ ឥឡូវបច្ចុប្បន្នខ្ញុំមិនដឹងស្លាប់នៅ គេនៅម្តុំសំពៅលូនម្តុំជាយដែនឯណោះ។

[១១:៥២:៤៩]

**ស៖** តើ អួន ណុប ជាប្រធានសហករណ៍មួយចិត្តល្អ ឬក៏យ៉ាងម៉េចដែរ? លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា ហេតុអីបានជាគេផ្តិតមេដៃទម្លាក់ អួន ណុប ហ្នឹង?

**ឆ៖** តាមមូលហេតុ ព្រោះគេចង់យកចំណុចឪពុកខ្ញុំឲ្យ គេចង់ផ្តួលឪពុកខ្ញុំ យកទៅសម្លាប់ចោល គេត្រូវជើងគ្នា អ្នកមេឃុំ ហើយនិងមេភូមិ។ គេរាយការណ៍ទៅ បើគេចាប់នៅ គេចាប់មិនកើត។ អ៊ីចឹងគេធ្វើជាល្បិចមួយដើម្បីឲ្យឪពុកខ្ញុំ ហើយបងថ្លៃខ្ញុំហ្នឹងធ្វើជាមីទិ្ទងសម្រាប់ឲ្យមានភស្តុតាងថា អ្នកឯងបានធ្វើរដ្ឋប្រហារមេភូមិ ទម្លាក់មេភូមិចោល តែជាមិន -- ប៉ុណ្ណឹងទេ ខ្ញុំដឹងប៉ុណ្ណឹង។

**ស៖** ពេលមានអង្គប្រជុំផ្តិតមេដៃទម្លាក់ប្រធានសហករណ៍ហ្នឹង លោកមានវត្តមាននៅក្នុងពេលប្រជុំហ្នឹងដែរទេ?

**ឆ៖** ខ្ញុំអត់មានវត្តមាននៅទីហ្នឹងទេ ខ្ញុំទៅឃ្វាលគោ ខ្ញុំត្រឡប់មកវិញបានគេប្រាប់ខ្ញុំថា "អី! គេធ្វើមីទិ្ទងទម្លាក់មេភូមិ" ម្អែងគ្រប់គ្នាអត់មក? ខ្ញុំថា ខ្ញុំមកអីជាប់មើលគោហ្នឹង។ ខ្ញុំឆ្លើយជាមួយគេអ្នកប្រាប់ខ្ញុំហ្នឹង តែប៉ុណ្ណឹង។

[១១:៥៤:៣៨]

**ស៖** តើបន្ទាប់ពីកិច្ចប្រជុំហ្នឹងរយៈពេលប៉ុនណាដែលគេចាប់ខ្លួនឪពុកលោកហ្នឹង បន្ទាប់ពីកិច្ចប្រជុំហ្នឹង លឿនប៉ុនណាដែរ?

**ឆ៖** ឪពុកខ្ញុំវិលងមួយយប់។ មួយយប់ពេលវេលាថ្ងៃត្រង់ ពេលខ្ញុំត្រឡប់ពីមើលគោស៊ីបាយសហករណ៍ឃើញគេ ពួកឈ្លបគេមកបីនាក់ គេមកបណ្ដើរខ្ញុំថា ឲ្យទៅជួបនឹងអង្គការមួយភ្លែត ឲ្យឪទុកកាំបិតចោល ហើយឪពុកខ្ញុំហុចចានមួយ ស្លាបព្រាមួយ កាំបិតឲ្យមកខ្ញុំ ហើយប្រាប់ថា៖ "កូនឯងទៅផ្ទះទៅ"។

**ស៖** ទាក់ទងទៅនឹងពេលដែលគេចាប់ឪពុករបស់លោក តើលោកពេលណាដែលលោក ហើយនិងសមាជិកគ្រួសាររបស់លោកដទៃទៀតហ្នឹងត្រូវខ្មែរក្រហមចាប់ខ្លួន?

**ឆ៖** រយៈពេល៥ថ្ងៃ បានគេមកប្រមូលម្ដាយខ្ញុំ និងបងប្អូនខ្ញុំតូចតាចយកទៅ ហើយអ្នកភូមិជាមួយគ្នាហ្នឹង អ្នកភូមិ សុក សុត, សុក សាន, សឿ សុមើ, សួន យ៉ា ហ្នឹងបានគេប្រមូលទៅមួយឡានដាក់ទៅក្នុងគុកអង្គរកា។ គុកអង្គរកា ដាក់ក្នុងហ្នឹងមួយយប់ ហើយស្អែកឡើងបានបន្តពីគុកអង្គរកាទៅ ពីម៉ោងបីរសៀល យកទៅដល់ក្រាំងតាចាន់។

**ស៖** សូមអរគុណលោក មាស សុខា។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតចូលសួរឯកសារមួយផ្សេងទៀត។ ប៉ុន្តែដោយសារថា ពេលវេលាជិតនឹងដល់ម៉ោងដប់ពីរទៅហើយ ថាតើលោកប្រធានគួរឈប់សម្រាកសិន ឬក៏អនុញ្ញាតឲ្យខ្ញុំបន្តទៀត?

**ប្រធានអង្គជំនុំ៖**

បន្តទៀតចុះ។

[១១:៥៧:១៣]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ទី១ លោកឆ្លើយថា គេចាប់លោកយកទៅអង្គរកាមុនសិន។ អ៊ីចឹងតើលោកអាចរៀបរាប់ជូនអង្គជំនុំជម្រះបន្តិចមើលថាតើ គុកអង្គរកាហ្នឹងស្ថិតនៅទីកន្លែងណា? ហើយវាមាន

ស្ថានភាព វាមានអគារមានអីហ្នឹងលក្ខណៈបែបណាដែរ?

**លោក មាស សុខា៖**

**ឆ៖** គុកអង្គរកាហ្នឹង គេដាក់បណ្ដោះអាសន្នសម្រាប់នាំមនុស្សយកទៅ បញ្ជូនទៅក្រាំងតាចាន់ ដែលផ្ទះគុក អគារគុកហ្នឹង គឺផ្ទះថ្មពីជំនាន់ចាស់មួយខ្នង មួយល្វែង ដាក់សម្រាប់ប្រមូលពីភូមិនានាយកមកដាក់នៅកន្លែងហ្នឹង។

**ស៖** តើមានអ្នកទោសផ្សេងទៀតត្រូវបានគេឃុំខ្លួន -- តើខ្មែរក្រហមមានឃុំខ្លួនអ្នកដទៃទៀតនៅគុកអង្គរកាដែរទេពេលដែលលោកទៅដល់គុកអង្គរកានុ៎ង?

[១១:៥៨:៤២]

**ឆ៖** ពេលនោះខ្ញុំអត់មានឃើញមនុស្សណានៅក្នុងគុកនោះទេ មានតែក្រុមគ្រួសារខ្ញុំ គ្រាន់តែឃើញស្នាមឈាម ស្នាមប្រឡាក់ឈាមតែប៉ុណ្ណឹង។ ឃើញតែខ្នោះ ឃើញតែខ្នោះដាក់ជើង ខ្នោះដាក់អីហ្នឹង។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេថា តើមន្ទីរស្រុកត្រាំកក់កាលនោះស្ថិតនៅកន្លែងណាដែរ? តើវាមានទំនាក់ទំនងយ៉ាងម៉េចដែរជាមួយនឹងគុកអង្គរកា?

**ឆ៖** មន្ទីរស្រុកខ្ញុំអត់បានដឹងកន្លែងណាពិតប្រាកដ ព្រោះមន្ទីរស្រុកខ្ញុំអត់ដឹង ខ្ញុំដឹងតែគេចាប់ខ្លួនទៅយកទៅដាក់នៅអង្គរកាហ្នឹង រឿងមន្ទីរស្រុកខ្ញុំអត់ដឹង ព្រោះសម័យនោះអត់ដឹងទេ រឿងមន្ទីរស្រុកនោះ ព្រោះស្រុកគេដើរដាក់រកេតរកូតគ្រប់កន្លែង ផ្ទះមួយក៏អាចធ្វើមន្ទីរស្រុកបានដែរ ព្រោះខ្មែរក្រហមមិនអាចមានទីតាំងពិតប្រាកដ។

**ស៖** ខ្ញុំសុំសួរទៅថា បន្ទាប់ពីគេឃុំនៅគុកអង្គរកា តើគេបញ្ជូនលោកទៅទីណាទៀត?

**ឆ៖** ឃុំនៅអង្គរកាមួយយប់ហើយ ម៉ោងបីរសៀលគេបញ្ជូនទៅក្រាំងតាចាន់តែម្ដង ហើយគេបញ្ចូលទៅក្នុងអគារគុកតែម្ដង។

**ស៖** នៅពេលលោកទៅដល់គុកក្រាំងតាចាន់ តើលោកបានជួបឪពុកលោកនៅទីនោះទេ?

**ឆ៖** ពេលទៅដល់គុកក្រាំងតាចាន់ ខ្ញុំពុំបានឃើញឪពុកខ្ញុំទេ ឃើញតែលោកយាយ ស៊ិន គាត់ប្រាប់ថា “ឪពុកហ្អែងគេយកទៅក្រៅហើយ” ខ្ញុំឃើញតែដែកកេះគាត់ទេ។ “ពីរនាក់បងប្អូនហ្អែង គេវៃគាត់ឡើងទន់ខ្លួន”។ គាត់ប្រាប់តែប៉ុណ្ណឹង។

**ស៖** តើលោកមានដែលបានជួបឪពុកលោកទៀតទេ បន្ទាប់ពីហ្នឹង មកក្រោយៗមកទៀត?

[១២:០១:៤៣]

**ឆ៖** គេអត់ឲ្យខ្ញុំជួបទេ រឿងសាច់ញាតិ តែឃើញគឺគេអត់ឲ្យឃើញផង។ មិនមែនថាអ្នកជាប់នៅក្នុងហ្នឹងទេ គេកម្រឲ្យឃើញណាស់។

**ស៖** សំណួររបស់ខ្ញុំហ្នឹងសួរថាដូច្នេះ បន្ទាប់ពីគេបញ្ជូនលោកចេញក្រៅគុកក្រាំងតាចាន់ហ្នឹងនេះ តើលោកមានបានជួបម្ដាយលោក បងប្អូនលោក និងឪពុកលោកនៅពេលណាម្ដងទៀតទេ?

**ឆ៖** ឪពុកខ្ញុំអត់ជួបរហូត នៅតែម្ដាយខ្ញុំនៅជុំគ្នាជាមួយបងប្អូនតូចតាច ជាមួយបងស្រីខ្ញុំហ្នឹង ហើយក្មួយប្រុសៗពីរហ្នឹង។ រឿងឪពុកគេយកសម្លាប់មុនខ្ញុំចេញវាលហ្នឹងហើយ គេបញ្ចេញឲ្យធ្វើការ។

**ស៖** សូមឲ្យលោករៀបរាប់ជូនតុលាការបន្តិចអំពីគុកក្រាំងតាចាន់ហ្នឹង។ តើបរិវេណគុកក្រាំងតាចាន់ហ្នឹងវាធំប៉ុន្មានដែរ? លោក សូមលោករៀបរាប់ជាទូទៅអំពីស្ថានភាពទូទៅ ទំហំ និងលក្ខណៈរបស់គុកក្រាំងតាចាន់ ជូនតុលាការស្ដាប់បន្តិច។

**ឆ៖** បរិវេណគុកក្រាំងតាចាន់ ប្រជាជននៅទីតាំងក្បែរហ្នឹង គេដេញចេញចម្ងាយដីមួយគីឡូជុំវិញទាំងអស់ ប៉ុន្តែគេធ្វើបរិវេណគុកក្នុងហ្នឹងយ៉ាងច្រើនបំផុតដីចំនួនបីហិកតាចុះ សម្រាប់គេពង្រីកទៅដល់ដីចំនួនមួយគីឡូបួនជ្រុងហ្នឹង។

**ស៖** តើគុកហ្នឹងមានរបងព័ទ្ធជុំវិញដែរឬទេ?

[១២:០៤:០៧]

**ឆ៖** គុកហ្នឹងមានរបងលួសពីរជាន់។ ក្នុងអគារមានលួសបន្លាព័ទ្ធជុំវិញក្នុងអគារ ក្នុងជញ្ជាំងក្រោមរនាប ពីក្រោមដំបូល វាវែងដូចក្រឡាវែកអ៊ីចឹង។

**ស៖** នៅក្នុងរបងលួសបន្លាខាងក្នុងនោះ ជាន់ខាងក្នុងនោះ តើមានអគារប៉ុន្មានដែលគេព័ទ្ធទៅដោយលួសបន្លាហ្នឹង?

**ឆ៖** មានអគារបីខ្នងសម្រាប់ដាក់មនុស្ស គុក អ្នកទោស។ អគារសម្រាប់គេអ្នកស្នាក់នៅបុគ្គលិកគេមានអគារមួយ ហើយនិងធ្វើរោងតូចតាចពីរបី ធ្វើចង្ក្រានបាយគេ ហើយកន្លែងគេសួរអ្នកទោសមួយកន្លែងទៀត។

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ ឥឡូវដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទី

រសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សីក្នុងអំឡុងពេលនៃការឈប់សម្រាក និងឲ្យនាំខ្លួនគាត់ចូលមកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាងក្រោម ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៦ នាទី ដល់ម៉ោង ១៣:៥១ នាទី)*

[១៣:៥១:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

នៅរសៀលនេះ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី និងសាធារណជនបានជ្រាបថា អង្គជំនុំជម្រះសាលាដំបូងមិនអាចបន្តកិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សី លោក មាស សុខា បានទេ ដោយមូលហេតុ អង្គជំនុំជម្រះបានទទួលនូវលិខិតរបស់ពេទ្យប្រចាំការនៅ អ.វ.ត.ក នេះ បញ្ជាក់ថា លោក ខៀវ សំផន មានអាការៈវិលមុខខ្លាំង ហើយនិងសំពាធឈាមឡើងខ្ពស់ ហើយឥឡូវនេះ គឺខាងគ្រូពេទ្យប្រចាំការនៅ អ.វ.ត.ក សម្រេចបញ្ជូនគាត់ទៅទទួលការពិនិត្យ និងព្យាបាលនៅឯមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

ដោយសារមូលហេតុជនជាប់ចោទមួយរូប ដែលគាត់មានអាការៈដូច្នេះ ហើយមិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការបាន ដូច្នេះអង្គជំនុំជម្រះមិនអាចដំណើរការសវនាការ ដោយអវត្តមានជនជាប់ចោទរបៀបនេះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចប្រកាសផ្អាកកិច្ចដំណើរការសវនាការនៅរសៀលនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ចាប់ផ្តើមដូចសព្វដង គឺចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

អង្គជំនុំជម្រះសូមអញ្ជើញភាគីនិងសាក្សី មាស សុខា សូមអញ្ជើញមកផ្ដល់សក្ខីកម្ម មកចូលរួមដំណើរការសវនាការនៅថ្ងៃស្អែក។ ចំពោះព្រឹត្តិការណ៍យ៉ាងណានៅថ្ងៃស្អែកនោះ អាស្រ័យទៅលើស្ថានភាពនៃអាការៈជំងឺរបស់លោក ខៀវ សំផន ថាតើគាត់អាចវិលត្រឡប់មកធម្មតា ហើយអាចចូលរួមសវនាការនៅថ្ងៃស្អែកបានដែរឬទេ។ នោះគឺអង្គជំនុំជម្រះនឹងសម្រេចជាក់លាក់នៅថ្ងៃស្អែក ចាប់ផ្ដើមវេលាម៉ោងប្រាំបួនព្រឹក។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនៅថ្ងៃស្អែកឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមនៅក្នុងសវនាការនៅក្នុងបន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

[១៣:៥៣:១៥]

ដោយឡែកករណីលោក ខៀវ សំផន ប្រសិនបើអាការៈគាត់បានធូរស្រាល ហើយបានវិលត្រឡប់មកទាន់ពេលក៏ឲ្យនាំខ្លួនគាត់មកចូលរួមនៅសវនាការផងដែរ។ ហើយក្នុងករណីផ្សេងទៀត សូមឲ្យខាងគ្រូពេទ្យប្រចាំការផ្ដល់ព័ត៌មានជាបន្ទាន់អំពីបញ្ហាពាក់ព័ន្ធនឹងសុខភាពរបស់លោក ខៀវ សំផន ក្នុងការទទួលការពិនិត្យ និងព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតនេះ ដើម្បីអង្គជំនុំជម្រះត្រៀមរៀបចំកិច្ចដំណើរការសវនាការ ឬក៏ផែនការដំណើរការទៅថ្ងៃមុខ ជាពិសេសថ្ងៃស្អែកឲ្យបានត្រឹមត្រូវឲ្យបានល្អ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៣:៥៤នាទី)*